ក

មាតិកា

I~ព្រះរាជខុទ្ទកាល័យព្រះមហាក្សត្រ

ព្រះរាជក្រឹត្យ

០៦-៣-២០១៣ -ព្រះរាជក្រឹត្យ នស/រកត/០៣១៣/២០៩ ស្តីពី ការតែងតាំងលោក **ហេង សុផាត** ជា ឧកញ៉ា ២៤០១

០៦-៣-២០១៣ -ព្រះរាជក្រឹត្យ នស/រកត/០៣១៣/២១០ ស្តីពី ការដំឡើងឋានន្តរស័ក្តិ ជូនឯកឧត្តម **ឈឿង ផល្លាង** ពីឋានន្តរស័ក្តិ មន្ត្រីបច្ចេកទេសជាន់ខ្ពស់ដើមខ្សែ ថ្នាក់លេខ ៧ ទៅឋានន្តរស័ក្តិ មន្ត្រីបច្ចេកទេសជាន់ខ្ពស់ដើមខ្សែពិសេស ថ្នាក់លេខ ៦ នៃក្របខ័ណ្ឌមន្ត្រីបច្ចេកទេសជាន់ខ្ពស់ ក្រសួងសាធារណការ និង ដឹកជញ្ជូន ២៤០២

០៦-៣-២០១៣ -ព្រះរាជក្រឹត្យ នស/រកត/០៣១៣/២១១ ស្តីពី ការប្តូរប្រភេទក្របខ័ណ្ឌស្របតាមឧបនិស្ស័យមុខតំណែង ជូនមន្ត្រីរាជការ ចំនួន ០៦ រូប ពីឋានន្តរស័ក្តិនាយក្រមការនៃក្របខ័ណ្ឌមន្ត្រីក្រមការ ទៅឋានន្តរស័ក្តិអនុមន្ត្រីការបរទេស នៃក្របខ័ណ្ឌមន្ត្រីការទូតជាន់ខ្ពស់ ជាករណីពិសេស ២៤០៣

០៦-៣-២០១៣ -ព្រះរាជក្រឹត្យ នស/រកត/០៣១៣/២១២ ស្តីពី ការប្តូរប្រភេទក្របខ័ណ្ឌស្របតាមសញ្ញាបត្រ និង មុខតំណែង ជូនមន្ត្រីរាជការក្រសួងសាធារណការ និង ដឹកជញ្ជូន ចំនួន ១០ រូប ពីឋានន្តរស័ក្តិមន្ត្រីបច្ចេកទេសមធ្យមដើមខ្សែពិសេស និង ក្របខ័ណ្ឌ មន្ត្រីបច្ចេកទេសមធ្យមដើមខ្សែ ទៅឋានន្តរស័ក្តិមន្ត្រីបច្ចេកទេសជាន់ខ្ពស់ ២៤០៥

០៦-៣-២០១៣ -ព្រះរាជក្រឹត្យ នស/រកត/០៣១៣/២១៣ ស្តីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស តាមលំដាប់ថ្នាក់ ចំពោះ ថ្នាក់ដឹកនាំ ទីប្រឹក្សាក្រសួង មន្ត្រីរាជការចំនួន ២៧ រូប នៃក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ ២៤០៧

០៦-៣-២០១៣ -ព្រះរាជក្រឹត្យ នស/រកត/០៣១៣/២១៤ ស្តីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស តាមលំដាប់ថ្នាក់ចំពោះ ឯកឧត្តម ឧកញ៉ា និង អស់លោក ចំនួន ០៨ រូប ២៤០៩

II~រាជរដ្ឋាភិបាល

១~អនុក្រឹត្យ

០៥-៣-២០១៣ -អនុក្រឹត្យលេខ ៩១ អនក្រ.បក ស្តីពី ការធ្វើអនុបយោគ ប្តូរចំណាត់ថ្នាក់ពីទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ មកជាទ្រព្យសម្បត្តិឯកជនរបស់រដ្ឋ ២៤១០

០៦-៣-២០១៣ -អនុក្រឹត្យលេខ ៩២ អនក្រ.បក ស្តីពី ការកាត់ដីទំហំ ៣២៣,១៨ ហិកតា នៅស្រុកថ្មពួក ខេត្តបន្ទាយមានជ័យ ចេញពីគម្របព្រៃឈើឆ្នាំ ២០០២ និងធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ សម្រាប់ធ្វើប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ ចំនួន ២១៣ គ្រួសារ និង រក្សាទុកមួយចំណែកជាដីសាធារណៈរបស់រដ្ឋ ២៤១២

០៦-៣-២០១៣ -អនុក្រឹត្យលេខ ៩៣ អនក្រ.បក ស្តីពី ការកាត់ដីសរុបទំហំ ៣.៩៧៧,៤៨ ហិកតា នៅស្រុកភ្នំក្រវាញ ខេត្តពោធិ៍សាត់ ក្នុងនោះកាត់ចេញពីគម្របព្រៃឈើឆ្នាំ ២០០២ កាត់ចេញពីព្រៃសម្បទានក្រុមហ៊ុន យូរីសាគរ និងកាត់ចេញពីដីរបស់ក្រុមហ៊ុន តួច ហ៊ារ អ៊ិនខូបរ៉េសិន និង ដើម្បីធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ សម្រាប់ធ្វើប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ ៨៧៧ គ្រួសារ និង សម្រាប់គោលដៅសម្បទានដីសេដ្ឋកិច្ចខ្នាតតូច ហើយរក្សាទុកមួយចំណែកជាដីសាធារណៈរបស់រដ្ឋ ២៤១៦

០៨-៣-២០១៣ -អនុក្រឹត្យលេខ ៩៤ អនក្រ.បក ស្តីពី ការកាត់ដីទំហំ ៣០០,២៦៨៦ ហិកតា នៅស្រុកអូរជុំ ខេត្តរតនគិរី ចេញពីដីសម្បទានសេដ្ឋកិច្ចរបស់ក្រុមហ៊ុន ស៊ី អ ឌី សម្រាប់ធ្វើប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ ៧៩ គ្រួសារ និង រក្សាទុកមួយចំណែកសម្រាប់កំណើនប្រជាពលរដ្ឋ និង ហេដ្ឋារចនាសម្ព័ន្ធរូបវន្ត និង ផ្តល់សិទ្ធិជាកម្មសិទ្ធិលើក្បាលដី ២៤២២

០៨-៣-២០១៣ -អនុក្រឹត្យលេខ ៩៥ អនក្រ.បក ស្តីពី ការកាត់ដីសរុបទំហំ ១.៣០០,០២៦៧ ហិកតា នៅស្រុកអណ្តូងមាស ខេត្តរតនគិរី ចេញពីដីសម្បទានសេដ្ឋកិច្ចរបស់ក្រុមហ៊ុន វ៉ាសនា អិនវេសមេន សម្រាប់ធ្វើប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ៧៨ គ្រួសារ និង រក្សាទុកមួយចំណែកសម្រាប់កំណើនប្រជាពលរដ្ឋ និង ហេដ្ឋារចនាសម្ព័ន្ធរូបវន្ត និង ផ្តល់សិទ្ធិជាកម្មសិទ្ធិលើក្បាលដី ២៤២៥

០៨-៣-២០១៣ -អនុក្រឹត្យលេខ ៩៦ អនក្រ.បក ស្តីពី ការកាត់ដីទំហំ ៦១៨,២៩៤១ ហិកតា នៅស្រុកអណ្តូងមាស ខេត្តរតនគិរី ចេញពីដីសម្បទានសេដ្ឋកិច្ចរបស់ក្រុមហ៊ុន ជាំងលី សម្រាប់ធ្វើប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ ៦៤ គ្រួសារ និង រក្សា ទុកមួយចំណែកសម្រាប់កំណើនប្រជាពលរដ្ឋ និង ហេដ្ឋារចនាសម្ព័ន្ធរូបវន្ត និង ផ្តល់សិទ្ធិជាកម្មសិទ្ធិលើក្បាលដី ២៤២៨

០៨-៣-២០១៣ -អនុក្រឹត្យលេខ ៩៧ អនក្រ.បក ស្តីពី ការកាត់ដីសរុបទំហំ ១.៤២៥,៦២៨០ ហិកតា នៅស្រុកអណ្តូងមាស ខេត្តរតនគិរី ក្នុងនោះកាត់ចេញពីដីសម្បទានសេដ្ឋកិច្ច របស់ក្រុមហ៊ុន ហេង ប្រាឌ័រ និង កាត់ចេញពីដីសម្បទានសេដ្ឋកិច្ចរបស់ក្រុមហ៊ុន ក្រុងបុក អភិវឌ្ឍន៍ និង ធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ និងកាត់ចេញពីដីសម្បទានសេដ្ឋកិច្ចរបស់ក្រុមហ៊ុនវាសនា អិនវេសមេន សម្រាប់ធ្វើប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ ១៨៩ គ្រួសារ និង រក្សាទុកមួយ ចំណែកសម្រាប់កំណើនប្រជាពលរដ្ឋ និង ហេដ្ឋារចនាសម្ព័ន្ធរូបវន្ត និង ផ្តល់សិទ្ធិជា កម្មសិទ្ធិលើក្បាលដី ២៤៣១

០៨-៣-២០១៣ -អនុក្រឹត្យលេខ ៩៨ អនក្រ.បក ស្តីពី ការកាត់ដីទំហំ ៦៣៣,៩៧៧០ ហិកតា នៅស្រុកអូរជុំ ខេត្តរតនគិរី ចេញពីដីសម្បទានសេដ្ឋកិច្ចរបស់ក្រុមហ៊ុន ស៊ី អ ឌី សម្រាប់ធ្វើប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ ១៥១ គ្រួសារ និង រក្សាទុកមួយ ចំណែកសម្រាប់កំណើនប្រជាពលរដ្ឋ និង ហេដ្ឋារចនាសម្ព័ន្ធរូបវន្ត និង ផ្តល់សិទ្ធិជា កម្មសិទ្ធិលើក្បាលដី ២៤៣៤

០៧-១២-២០១២ -អនុក្រឹត្យលេខ **២៨២៧** ដល់អនុក្រឹត្យលេខ **២៨៥៨** អនក្រ.តត ស្តីពី ការជូន មេដាយការងារ ២៤៣៧

២-សេចក្តីសម្រេច

១១-៣-២០១៣-សេចក្តីសម្រេចលេខ ១០ សសរ ស្តីពី ការផ្ទេរសិទ្ធិការងាររបស់រាជរដ្ឋាភិបាល ២៤៦៩

III-ការងារបណ្តាក្រសួង

១-ទីស្តីការរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
និង
ក្រសួងបរិស្ថាន

២៨-១២-២០១២ -ប្រកាសរួមលេខ ៩៩៩ សហវ.ប្រក ស្តីពី ការផ្តល់សេវាសាធារណៈរបស់ ក្រសួងបរិស្ថាន ២៤៧០

២៨-១២-២០១២ -ប្រកាសរួមលេខ ១000 សហវ.ប្រក ស្តីពី ការផ្តល់រង្វាន់លើកទឹកចិត្តជូន ក្រសួងបរិស្ថាន និង ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ២៤៩០

២-ធនាគារជាតិ នៃ កម្ពុជា

៣១-១២-២០១២-ប្រកាសលេខ ធ ៧-០១២-១៨៥ ប្រក ស្តីពី វិធានប្រុងប្រយ័ត្ន និង ការគ្រប់គ្រងហានិភ័យអនុវត្តចំពោះគ្រឹះស្ថានធនាគារ និង ហិរញ្ញវត្ថុដែលធ្វើជាភ្នាក់ងារទូទាត់សាច់ប្រាក់ពាក់ព័ន្ធនឹងមូលបត្រ ២៥១២

ឃ

៣_ទីស្តីការរដ្ឋមន្ត្រីក្រសួងបរិស្ថាន

២៥-០១-២០១៣-ប្រកាសលេខ ០៥២ ប្រក.បស្ថ ស្តីពីការដាក់ឱ្យអនុវត្តប្រកាសរួមស្តីពីការ ផ្តល់សេវាសាធារណៈ និង ការផ្តល់រង្វាន់លើកទឹកចិត្តជូនក្រសួងបរិស្ថាន ២៥១៩

ព្រះរាជក្រឹត្យ

នស/រកត/០៣១៣/២០៩

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

ត្រាស់បង្គាប់

តែងតាំង :

លោក **ហេង សុផាត**

ជា

ឧកញ៉ា

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០៦ ខែ មីនា ឆ្នាំ ២០១៣

ក្នុងព្រះបរមនាម និងតាមព្រះរាជត្រាស់បង្គាប់
ប្រមុខរដ្ឋស្តីទី
ហត្ថលេខា និងព្រះរាជលញ្ឆករ
សម្តេចអគ្គមហាធម្មពោធិសាល ជា ស៊ីម

០៣៩៦.១៣០៣.២១១

លេខៈ ២១០ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី ១១ ខែ មីនា ឆ្នាំ២០១៣
អគ្គលេខាធិការរងទីស្តីការរាជរដ្ឋាភិបាល
ស៊ុយ សុខា

ព្រះរាជក្រឹត្យ

នស/រកត/០៣១៣/២១០

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៩ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃ ទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៦០២/១៥១ ចុះថ្ងៃទី ០៩ ខែ មិថុនា ឆ្នាំ ២០០២ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីបច្ចេកទេសជាន់ខ្ពស់
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៣ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសាធារណការ និងដឹកជញ្ជូន
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

ត្រាស់បង្គាប់

មាត្រា១ : ដំឡើងឋានន្តរស័ក្តិ ជូនឯកឧត្តម **ឈឿង ផល្លាង** ពីឋានន្តរស័ក្តិ មន្ត្រីបច្ចេកទេសជាន់ខ្ពស់ដើមខ្សែ ថ្នាក់លេខ ៧ ទៅឋានន្តរស័ក្តិ មន្ត្រីបច្ចេកទេសជាន់ខ្ពស់ដើមខ្សែពិសេស ថ្នាក់លេខ ៦ នៃក្របខ័ណ្ឌមន្ត្រីបច្ចេកទេសជាន់ខ្ពស់ ក្រសួងសាធារណការ និងដឹកជញ្ជូន ។

មាត្រា២ : សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវអនុវត្តឱ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ ។

មាត្រា៣ : ព្រះរាជក្រឹត្យនេះចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី ០៦ ខែ មីនា ឆ្នាំ ២០១៣

ក្នុងព្រះបរមនាម និងតាមព្រះរាជត្រាស់បង្គាប់
ប្រមុខរដ្ឋស្តីទី

ហត្ថលេខា និងព្រះរាជលញ្ឆករ
សម្តេចអគ្គមហាធម្មពោធិសាល ជា ស៊ីម

មាគសៈ១៣០៣.២១២

លេខៈ ២០៧ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ ០៣ ឆ្នាំ២០១៣
អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល

ស៊ួយ សុខា

ព្រះរាជក្រឹត្យ

នស/រកត/០៣១៣/៧១១

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រម លេខ នស/រកម/០១៩៦/០៩ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រម លេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យ លេខ នស/រកត/០៤០១/០៨៥ ចុះថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ២០០១ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីការទូតជាន់ខ្ពស់
- បានទ្រង់យល់ព្រះរាជក្រម លេខ នស/រកម/០១៩៦/១០ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

ត្រាស់បង្គាប់

មាត្រា ១: ប្តូរប្រភេទក្របខ័ណ្ឌស្របតាមឧបនិស្ស័យមុខតំណែង ជូនមន្ត្រីរាជការ ចំនួន ០៦ រូប ពីឋានន្តរស័ក្តិនាយក្រមការនៃក្របខ័ណ្ឌមន្ត្រីក្រមការ ទៅឋានន្តរស័ក្តិអនុមន្ត្រីការបរទេសនៃក្របខ័ណ្ឌមន្ត្រីការទូតជាន់ខ្ពស់ ជាករណីពិសេស ៖

ល.រ	គោត្តមនាម និង នាម	ភេទ	ក្របខ័ណ្ឌ ឋានន្តរស័ក្តិ និង ថ្នាក់	
			ចាស់	ស្នើសុំ
១	នូវ ស៊ីនឿន	ប	ខ.១.១	ក.៣.៦
២	អ៊ឹម ហេន	ប	ខ.១.១	ក.៣.៦
៣	ថោ ប៊ុនថា	ប	ខ.១.១	ក.៣.៦
៤	ហ៊ុន ប៊ុនធឿន	ស	ខ.១.២	ក.៣.៧

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS

៥	ថោង សុគន្ធារី	ស	ខ.១.២	ក.៣.៧
៦	អ៊ុក សោភ័ណ	ប	ខ.១.៦	ក.៣.១៤

មាត្រា ២: សម្ដេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវអនុវត្តឱ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ។

មាត្រា ៣: ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្ដលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី ០៦ ខែ មីនា ឆ្នាំ ២០១៣

ក្នុងព្រះបរមនាម និងតាមព្រះរាជបញ្ជាសប្ដាហ៍ ប្រមុខរដ្ឋស្ដីទី

នស.១៣០៣.២១៣

ហត្ថលេខា និងព្រះរាជលញ្ឆករ

សម្ដេចអគ្គមហាធម្មពោធិសាល ជា ស៊ីម

លេខៈ ៤១១ ច.ល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ ថ្ងៃទី ១១ ខែ មីនា ឆ្នាំ២០១៣

អគ្គលេខាធិការរងទី១រាជរដ្ឋាភិបាល

សុខា

ព្រះរាជក្រឹត្យ

នស/រកត/០៣១៣/២១៧

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រម លេខ នស/រកម/០១៩៦/០៩ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រម លេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យ លេខ នស/រកម/០៦០២/១៥១ ចុះថ្ងៃទី ០៩ ខែ មិថុនា ឆ្នាំ ២០០២ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីបច្ចេកទេសជាន់ខ្ពស់
- បានទ្រង់យល់ព្រះរាជក្រម លេខ នស/រកម/០១៩៦/០៣ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងសាធារណការ និងដឹកជញ្ជូន
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

ត្រាស់បង្គាប់

មាត្រា ១: ប្តូរប្រភេទក្របខ័ណ្ឌតាមសញ្ញាបត្រ និងមុខតំណែង ជូនមន្ត្រីរាជការក្រសួងសាធារណការ និងដឹកជញ្ជូន ចំនួន ១០ រូប ពីឋានន្តរស័ក្តិ មន្ត្រីបច្ចេកទេសមធ្យមដើមខ្សែពិសេស និងមន្ត្រីបច្ចេកទេសមធ្យមដើមខ្សែ ទៅឋានន្តរស័ក្តិ មន្ត្រីបច្ចេកទេសជាន់ខ្ពស់ ៖

ល.រ	គោត្តមនាម និង នាម	ភេទ	ក្របខ័ណ្ឌ ឋានន្តរស័ក្តិ និង ថ្នាក់	
			ចាស់	ស្នើសុំ
១	សូ សំណាង	ប	ខ.១.១	ក.៣.៦
២	ណុប ហេង	ប	ខ.១.១	ក.៣.៦
៣	គឹម សុវណ្ណ	ប	ខ.១.១	ក.៣.៦
៤	សរ គឹមណាត	ប	ខ.១.២	ក.៣.៧
៥	លឹម សុខទ្រី	ប	ខ.១.៣	ក.៣.៨

ROYAUME DU CAMBODGE · LE MINISTRE DU PALAIS

៦	ក្អែ ចន	ប	ឧ.១.៥	ក.៣.១២
៧	អ៊ុយ សុផល	ប	ឧ.១.៥	ក.៣.១២
៨	ស្រី សាខុន	ប	ឧ.១.៦	ក.៣.១៤
៩	ស្រេង សុង	ប	ឧ.១.៦	ក.៣.១៤
១០	ព្រំ ផូ	ប	ឧ.២.៩	ក.៣.១៤

មាត្រា ២: សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវអនុវត្តឱ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ។

មាត្រា ៣: ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០៦ ខែ មីនា ឆ្នាំ ២០១៣

ក្នុងព្រះបរមនាម និងតាមព្រះរាជបន្ទូលបង្គាប់

ប្រមុខរដ្ឋស្តីទី

ហត្ថលេខា និងព្រះរាជលញ្ឆករ

សម្តេចអគ្គមហាធម្មពោធិសាល ជា ស៊ីម

នស.១៣០៣.២១៤

លេខៈ ២១៣ ច.ល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ ថ្ងៃទី ១១ ខែ មីនា ឆ្នាំ២០១៣

អគ្គលេខាធិការរងទីស្តីការរាជរដ្ឋាភិបាល

សយ សុខា

ព្រះរាជក្រឹត្យ

នស/រកត/០៣១៣/២១៣

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

ប្រោសព្រះរាជទាន

ចំពោះ

ថ្នាក់ដឹកនាំ ទីប្រឹក្សាក្រសួង មន្ត្រីរាជការ ចំនួន ២៧ រូប នៃក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ មានគុណបំណាច់ខ្ពស់ និងស្នាដៃល្អជាច្រើន ចំពោះជាតិមាតុភូមិ លើវិស័យវប្បធម៌ និងវិចិត្រសិល្បៈ ដោយកន្លងមក ឯកឧត្តម លោកជំទាវ និងអស់លោក បានខិតខំអស់កម្លាំងកាយ-ចិត្ត ក្នុងការអភិរក្ស និងអភិវឌ្ឍនីវិស័យវប្បធម៌ ទទួលបានលទ្ធផលល្អ ប្រសើរតាមកម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាល

នូវ

ក- គ្រឿងឥស្សរិយយស **ជាតូបការ :**

១- ឯកឧត្តម **សំរ៉ាង កំសាន្ត**
២- ឯកឧត្តម **អ៊ុក សុជាតិ**
៣- ឯកឧត្តម **ថៃ នរៈសត្យា**
៤- លោកជំទាវ **ម៉ិញ កុសឌី**
៥- ឯកឧត្តម **សោម សុគន្ធ**

ខ- គ្រឿងឥស្សរិយយស **សម្តេចព្រះមហាក្សត្រីយានី ព្រះស៊ីសុវត្ថិមុនីវង្ស កុសុមៈនារីរ័ត្ន** ថ្នាក់ **មហាសេរីវឌ្ឍន៍ :**

១- ឯកឧត្តម **ពៅ ស៊ីង**
២- ឯកឧត្តម **មិន ចណ្ឌីណារុំធ**
៣- ឯកឧត្តម **ម៉ក់ សម្បត្តិ**

គ- គ្រឿងឥស្សរិយយស **ព្រះរាជាណាចក្រកម្ពុជា** ថ្នាក់ **មហាសេរីវឌ្ឍន៍ :**

១- លោកជំទាវ **សួស ណារ៉ា**
២- ឯកឧត្តម **សាយ មង្គល**

ឃ- គ្រឿងឥស្សរិយយស **មុនីសារាភ័ណ្ឌ** ថ្នាក់ **មហាសេរីវឌ្ឍន៍ :**

- ឯកឧត្តម **ម៉ៅ កេង**

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

ង- គ្រឿងឥស្សរិយយស **ព្រះរាជាណាចក្រកម្ពុជា** ថ្នាក់ **មហាសេនា** :

១- ឯកឧត្តម **អ៊ុន ទឹម** ៤- ឯកឧត្តម **បុង សុវត្ថិ**

២- ឯកឧត្តម **គង់ កន្តាវ៉ា** ៥- ឯកឧត្តម **ផាន់ សារ៉ាត់**

៣- ឯកឧត្តម **ស្រី សួន**

ច- គ្រឿងឥស្សរិយយស **ព្រះរាជាណាចក្រកម្ពុជា** ថ្នាក់ **ធិបឌិន្ទ** :

១- ឯកឧត្តម **ចំរើន វ៉ាន់ថា** ៥- ឯកឧត្តម **គ្រឿង ឈាង**

២- ឯកឧត្តម **ម៉េង ហួរ** ៦- ឯកឧត្តម **ឱក សុផុន**

៣- ឯកឧត្តម **ជឹង ឈង** ៧- ឯកឧត្តម **ហាប់ ទូច**

៤- ឯកឧត្តម **តូច សារុ** ៨- ឯកឧត្តម **សម សំអាង**

ឆ- គ្រឿងឥស្សរិយយស **ព្រះរាជាណាចក្រកម្ពុជា** ថ្នាក់ **សេនា** :

១- លោកជំទាវ **អឹង ស៊ីមន** ២- លោក **ម៉ុក គុណវុឌ្ឍ**

ជ- គ្រឿងឥស្សរិយយស **ព្រះរាជាណាចក្រកម្ពុជា** ថ្នាក់ **អស្សប្ញទ្ធិ** :

- លោក **ហ៊ឹម វិបុលផល**

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី ០៦ ខែ មីនា ឆ្នាំ ២០១៣

ក្នុងព្រះបរមនាម និងតាមព្រះរាជបន្ទូលបង្គាប់

ប្រមុខរដ្ឋស្តីទី

ហត្ថលេខា និងព្រះរាជលញ្ចករ

សម្តេចអគ្គមហាធម្មពោធិសាល ជា ស៊ីម

៣៧២.១៣០៣.២១៥

លេខ: ២១៧ ច.ល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ ថ្ងៃទី ១១ ខែ មីនា ឆ្នាំ២០១៣

អគ្គលេខាធិការរងទីស្តីការគណៈរដ្ឋមន្ត្រី

សយ សុខា

ព្រះរាជក្រឹត្យ

នស/រកត/០៣១៣/២១៤

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

ប្រោសព្រះរាជទាន

ចំពោះ

ឯកឧត្តម ឧកញ៉ា និងអស់លោក ចំនួន ០៨ រូប ដែលមានគុណបំណាច់ និងស្នាដៃល្អក្នុងការចូលរួម ជួយកសាងសមិទ្ធផលនានាលើវិស័យព្រះពុទ្ធសាសនានិងសង្គមជាតិ នៅក្នុងខេត្តពោធិ៍សាត់ កន្លងមក

នូវ

ក- គ្រឿងឥស្សរិយយស **ជាតូបការ** :

១- ឯកឧត្តម **លី ណារុន**   ២- លោក **កែម សុធឿន**

ខ- គ្រឿងឥស្សរិយយស **សម្តេចព្រះមហាក្សត្រីយានី ព្រះស៊ីសុវត្ថិមុនីវង្ស កុសុមៈនារីរ័ត្ន** ថ្នាក់ **មហាសេរីវឌ្ឍន៍** :

- ឧកញ៉ា **ថ្រី ភាព**

គ- គ្រឿងឥស្សរិយយស **ព្រះរាជាណាចក្រកម្ពុជា** ថ្នាក់ **មហាសេនា** :

- លោក **ហាន់ ស៊ីណាត**

ឃ- គ្រឿងឥស្សរិយយស **សុវត្ថារា** ថ្នាក់ **មហាសេនា** :

១- លោក **ឃៀង សុជីវ័ន្ត**   ២- លោក **រិទ្ធ ផល្លា**

ង- គ្រឿងឥស្សរិយយស **មុនីសារាភ័ណ្ឌ** ថ្នាក់ **មហាសេនា** :

១- លោក **វង្ស ចាន់ប៉ាញ**   ២- លោក **ហេង សំណាង**

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី ០៦ ខែ មីនា ឆ្នាំ ២០១៣

ក្នុងព្រះបរមនាម និងតាមព្រះរាជបញ្ជាស់បង្គាប់

ប្រមុខរដ្ឋស្តីទី

ហត្ថលេខា និងព្រះរាជលញ្ឆករ
សម្តេចអគ្គមហាធម្មពោធិសាល ជា ស៊ីម

៣៧៥.០៣០៣.២១៦

លេខ: ២០៧ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី១១ ខែមីនា ឆ្នាំ២០១៣
អគ្គលេខាធិការរាជរដ្ឋាភិបាល

សយ សុខា

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ: ៩១ អនក្រ.បក

អនុក្រឹត្យ

ស្តីពី

ការធ្វើអនុបយោគ ប្តូរចំណាត់ថ្នាក់ ពីទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ មកជាទ្រព្យសម្បត្តិឯកជនរបស់រដ្ឋ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត /០៩០៨ /១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម /០៨០១ /១៤ ចុះថ្ងៃទី ៣០ ខែ សីហា ឆ្នាំ ២០០១ ដែល ប្រកាសឱ្យប្រើច្បាប់ភូមិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម /០៨០៦ /៣៣៩ ចុះថ្ងៃទី ០៣ ខែ សីហា ឆ្នាំ ២០០៦ ស្តីពីគោលការណ៍និងបញ្ញត្តិអន្តរកាលនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និងរបស់នីតិបុគ្គលសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ១២៩ អនក្រ.បក ចុះថ្ងៃទី ២៧ ខែ វិច្ឆិកា ឆ្នាំ ២០០៦ ស្តីពីវិធាន និងនីតិវិធីនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និងរបស់នីតិបុគ្គលសាធារណៈ
- តាមសំណើ របស់ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ

សម្រេច

មាត្រា ១ :-

ត្រូវបានចាត់បញ្ចូលជាទ្រព្យសម្បត្តិឯកជនរបស់រដ្ឋនូវទីតាំង៖

-អគារលេខ ២០៥ ស្ថិតនៅផ្លូវលេខ២០៨ សង្កាត់បឹងរាំង ខណ្ឌដូនពេញ រាជធានីភ្នំពេញ មានផ្ទៃដីទំហំ ៥២៥ ម៉ែត្រក្រឡា។

-អគារលេខ ១៩៥ ស្ថិតនៅផ្លូវលេខ២០៨ សង្កាត់បឹងរាំង ខណ្ឌដូនពេញ រាជធានីភ្នំពេញ មានផ្ទៃដីទំហំ ៦៧៥ ម៉ែត្រក្រឡា។

-អគារលេខ ១៨៤ ស្ថិតនៅផ្លូវលេខ២០៨ សង្កាត់បឹងរាំង ខណ្ឌដូនពេញ រាជធានីភ្នំពេញ មានផ្ទៃដីទំហំ ៥២០ ម៉ែត្រក្រឡា។

-អគារលេខ ២០៨ ស្ថិតនៅផ្លូវលេខ២០០ សង្កាត់បឹងរាំង ខណ្ឌដូនពេញ រាជធានីភ្នំពេញ មានផ្ទៃដីទំហំ ១១២ ម៉ែត្រក្រឡា។

មាត្រា ២ :-

ការលប់ទីតាំងដូចមានចែងក្នុងមាត្រា ១ ចេញពីបញ្ជីសារពើភ័ណ្ឌទ្រព្យសម្បត្តិរដ្ឋត្រូវស្ថិតក្រោមការចាត់ចែងនីតិវិធីដោយ ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

មាត្រា ៣ :-

បទបញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះត្រូវចាត់ទុកជានិរាករណ៍ ។

មាត្រា ៤ :-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធត្រូវអនុវត្តអនុក្រឹត្យនេះឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ, ថ្ងៃទី ០៥ ខែ មិនា ឆ្នាំ២០១៣

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល :

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋាន ក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋាន ព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋាន រដ្ឋសភា
- អគ្គលេខាធិការដ្ឋាន រាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ដូចមាត្រា ៤
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ៩៧ អនក្រ.បក

អនុក្រឹត្យ

ស្តីពី

ការកាត់ដីទំហំ ៣២៣,១៨ ហិកតា នៅស្រុកថ្មពួក ខេត្តបន្ទាយមានជ័យ ចេញពីគម្រប ព្រៃឈើឆ្នាំ ២០០២ និងធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ សម្រាប់ធ្វើទានកម្មជាកម្មសិទ្ធិ ជូនប្រជាពលរដ្ឋ ២១៣ គ្រួសារ និងរក្សាទុកមួយចំណែកជាដីសាធារណៈរបស់រដ្ឋ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២នសចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ១៩៩៩ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១ ដែលប្រកាសឲ្យប្រើច្បាប់ភូមិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០២/០១៦ ចុះថ្ងៃទី៣១ ខែសីហា ឆ្នាំ២០០២ ដែលប្រកាសឲ្យ ប្រើច្បាប់ស្តីពីព្រៃឈើ
- បានឃើញព្រះរាជក្រឹត្យលេខនស/រកត/០៨០៦/៣៣៩ ចុះថ្ងៃទី០៣ ខែសីហា ឆ្នាំ២០០៦ ស្តីពីគោលការណ៍ និងបញ្ញត្តិអន្តរកាលនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋនិងរបស់នីតិបុគ្គលសាធារណៈ

- បានឃើញអនុក្រឹត្យលេខ៦២ អនក្រ.បក ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញអនុក្រឹត្យលេខ ១៧ អនក្រ.បក ចុះថ្ងៃទី០៧ ខែមេសា ឆ្នាំ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ៨៨ អនក្រ.បក ចុះថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០០០ ស្តីពីការបង្កើតក្រុមប្រឹក្សាគោលនយោបាយដីធ្លី
- បានឃើញអនុក្រឹត្យលេខ១១៨ អនក្រ.បក ចុះថ្ងៃទី០៧ ខែតុលា ឆ្នាំ២០០៥ ស្តីពីការគ្រប់គ្រងដីរដ្ឋ
- បានឃើញអនុក្រឹត្យលេខ១៤៦ អនក្រ.បកចុះថ្ងៃទី២៧ខែធ្នូ ឆ្នាំ២០០៥ ស្តីពីសម្បទានដីសេដ្ឋកិច្ច
- បានឃើញសារាចរលេខ ០២ សរ ចុះថ្ងៃទី២៦ ខែកុម្ភៈឆ្នាំ២០០៧ ស្តីពីការកាន់កាប់ដីរដ្ឋដោយខុសច្បាប់
- លិខិតលេខ ២៨៣ ខ.បជ ចុះថ្ងៃទី ២០ ខែ កុម្ភៈ ឆ្នាំ ២០១៣ របស់គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តបន្ទាយមានជ័យ
- យោងតាមការចាំបាច់របស់រាជរដ្ឋាភិបាល

សម្រេច

មាត្រា ១.-

ត្រូវបានកាត់ផ្ទៃដីទំហំ **៣២៣,១៨ ហិកតា** ចេញពីគម្របព្រៃឈើឆ្នាំ ២០០២ និងធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ សម្រាប់ធ្វើប្រទានកម្មទំហំ **៣១២,៣៦ ហិកតា** ជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ និងទំហំ **១០,៨២ ហិកតា** រក្សាទុកជាដីសាធារណៈរបស់រដ្ឋ នៅភូមិថ្មីកណ្តាល ឃុំភូមិថ្មី ស្រុកថ្មពួក ខេត្តបន្ទាយមានជ័យ តាមប្រព័ន្ធកូអរដោណេ Project UTM Zone 48N Datum WGS 1984 និងមាននិយាមកាដូចកំណត់ក្នុងផែនទីឧបសម្ព័ន្ធនៃអនុក្រឹត្យនេះ ។

មាត្រា ២.-

ត្រូវបានប្រគល់អាណត្តិកាន់កាប់ និងបែងចែកដីរបស់រដ្ឋដូចមានចែងក្នុងមាត្រា ១ ជូនគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តបន្ទាយមានជ័យ ធ្វើការគ្រប់គ្រង និងប្រទានកម្មជាកម្មសិទ្ធិឯកជនជូនប្រជាពលរដ្ឋ ចំនួន **២១៣ គ្រួសារ** ដែលបានកាន់កាប់ ប្រើប្រាស់ និងដាំដុះជាក់ស្តែង នៅភូមិថ្មីកណ្តាល ឃុំភូមិថ្មី ស្រុកថ្មពួក ខេត្តបន្ទាយមានជ័យ ។

មាត្រា ៣.-

ក្នុងពេលដំណើរការវាស់វែង និងបែងចែកជាក់ស្តែង គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តបន្ទាយមានជ័យ ត្រូវកាត់ចេញនូវចំណែកដីមួយចំនួនសមស្រប ដើម្បីរក្សាទុកសម្រាប់បម្រើផលប្រយោជន៍សាធារណៈ ជាអាទិ៍ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវន្ត និងសង្គម នៅក្នុងមូលដ្ឋាន។

មាត្រា ៤.-

បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយពីអនុក្រឹត្យនេះត្រូវចាត់ទុកជានិរាករណ៍ ។

មាត្រា ៥.-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រីក្រសួងបរិស្ថាន រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ និងអភិបាលនៃគណៈអភិបាលខេត្តបន្ទាយមានជ័យ ត្រូវអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែ មីនា ឆ្នាំ២០១៣

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល៖

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការ រាជរដ្ឋាភិបាល*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា*
- *អគ្គលេខាធិការដ្ឋានអាជ្ញាធរជាតិដោះស្រាយវិវាទដីធ្លី*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ៥*
- *រាជកិច្ច*
- *ឯកសារកាលប្បវត្តិ*

ឧបសម្ព័ន្ធនៃអនុក្រឹត្យលេខ ៥៧ អនក្រ.បក ចុះថ្ងៃទី ០៧ ខែ មីនា ឆ្នាំ ២០១៣ ស្តីពីការកាត់ដីទំហំ ៣២៣,១៨ ហិកតានៅស្រុកថ្មពួក ខេត្តបន្ទាយមានជ័យចេញពីគម្របព្រៃឈើឆ្នាំ ២០០២ និងធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ សម្រាប់ធ្វើប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ ២១៣ គ្រួសារ និងរក្សាទុកមួយចំណែកជាដីសាធារណៈរបស់រដ្ឋ



ចំណុចនិយាមការ

UTM Zone 48N Datum WGS84

Code	X_Coor	Y_Coor	Code	X_Coor	Y_Coor
P1	295643	1540479	P23	297501	1539163
P2	295726	1540562	P24	297373	1539009
P3	295765	1540583	P25	297220	1538826
P4	295836	1540590	P26	297183	1538782
P5	296036	1540602	P27	297074	1538894
P6	296100	1540786	P28	296921	1538976
P7	296153	1540800	P29	296750	1539029
P8	296373	1540840	P30	296708	1539043
P9	296746	1540907	P31	296618	1539123
P10	296905	1540936	P32	296589	1539167
P11	297348	1541016	P33	296580	1539257
P12	297603	1541062	P34	296572	1539343
P13	297866	1541110	P35	296578	1539427
P14	298134	1541158	P36	296456	1539606
P15	297965	1540591	P37	296156	1539785
P16	297930	1540468	P38	296073	1539838
P17	297835	1540132	P39	295945	1540018
P18	297784	1539949	P40	295872	1540125
P19	297740	1539795	P41	295847	1540166
P20	297712	1539696	P42	295834	1540187
P21	297648	1539470	P43	295823	1540333
P22	297608	1539328			



ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ៩៣ អនក្រ.បក

អនុក្រឹត្យ

ស្តីពី

ការកាត់ដីសរុបទំហំ ៣.៥៧៧,៤៨ ហិកតា នៅស្រុកភ្នំក្រវ៉ាញ ខេត្តពោធិ៍សាត់ ក្នុងនោះ កាត់ចេញពីគម្របព្រៃឈើឆ្នាំ ២០០២ កាត់ចេញពីព្រៃសម្បទានក្រុមហ៊ុន យូរីសាគរ និង កាត់ចេញពីដីរបស់ក្រុមហ៊ុន តួច ហ៊ាង អ៊ិនខូបរ៉េសិន និងធ្វើអនុបយោគជាដីឯកជន របស់រដ្ឋ សម្រាប់ធ្វើប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ ៨៧៧ គ្រួសារ និងសម្រាប់ គោលដៅសម្បទានដីសេដ្ឋកិច្ចខ្នាតតូច ហើយរក្សាទុកមួយចំណែកជាដីសាធារណៈរបស់រដ្ឋ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២នសចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ១៩៩៩ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១ ដែលប្រកាសឲ្យប្រើច្បាប់ភូមិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០២/០១៦ ចុះថ្ងៃទី៣១ ខែសីហា ឆ្នាំ២០០២ ដែលប្រកាសឲ្យ ប្រើច្បាប់ស្តីពីព្រៃឈើ

- បានឃើញព្រះរាជក្រឹត្យលេខនស/រកត/០៨០៦/៣៣៩ ចុះថ្ងៃទី០៣ ខែសីហា ឆ្នាំ២០០៦ ស្តីពីគោលការណ៍ និងបញ្ញត្តិអន្តរកាលនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋនិងរបស់នីតិបុគ្គលសាធារណៈ
- បានឃើញអនុក្រឹត្យលេខ៦២ អនក្រ.បក ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញអនុក្រឹត្យលេខ ១៧ អនក្រ.បក ចុះថ្ងៃទី០៧ ខែមេសា ឆ្នាំ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ៨៨ អនក្រ.បក ចុះថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០០០ ស្តីពីការបង្កើតក្រុមប្រឹក្សាគោលនយោបាយដីធ្លី
- បានឃើញអនុក្រឹត្យលេខ១១៨ អនក្រ.បក ចុះថ្ងៃទី០៧ ខែតុលា ឆ្នាំ២០០៥ ស្តីពីការគ្រប់គ្រងដីរដ្ឋ
- បានឃើញអនុក្រឹត្យលេខ១៤៦ អនក្រ.បកចុះថ្ងៃទី២៧ខែធ្នូ ឆ្នាំ២០០៥ ស្តីពីសម្បទានដីសេដ្ឋកិច្ច
- បានឃើញសារាចរលេខ ០២ សរ ចុះថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០០៧ ស្តីពីការកាន់កាប់ដីរដ្ឋដោយខុសច្បាប់
- លិខិតលេខ ០៣០៣ ខ.ពស ចុះថ្ងៃទី ១៥ ខែ កុម្ភៈ ឆ្នាំ ២០១៣ របស់គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តពោធិ៍សាត់
- យោងតាមការចាំបាច់របស់រាជរដ្ឋាភិបាល

សម្រេច

មាត្រា ១.-

ត្រូវបានកាត់ផ្ទៃដីសរុបទំហំ ៣.៥៧៧,៥៨ ហិកតា ក្នុងនោះ (១) ទំហំ ៤០២.៨៥ ហិកតា កាត់ចេញពីគម្រប់ព្រៃឈើឆ្នាំ ២០០២ និង(២) ទំហំ ១.៦៣១,៧៩ ហិកតា កាត់ចេញពីព្រៃសម្បទានក្រុមហ៊ុន យូរីសាគរ និង(៣)ទំហំ ១.៥៤២,៨៤ ហិកតា កាត់ចេញពីដីរបស់ក្រុមហ៊ុន តូច ហ៊ារ អ៊ិនខូបរ៉េសិន និងធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ សម្រាប់ធ្វើប្រទានកម្មទំហំ ២.២៩៧,៤៥ ហិកតា ជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ និងទំហំ ១.០៧៩,២៩ ហិកតា សម្រាប់គោលដៅសម្បទានសេដ្ឋកិច្ចខ្នាតតូច ហើយទំហំ ២០០,៧៤ ហិកតា រក្សាទុកជាដីសាធារណៈរបស់រដ្ឋ នៅឃុំ ផ្ទះរុង ស្រុកភ្នំក្រវ៉ាញ ដែលស្ថិតក្នុងភូមិ ដូចខាងក្រោម ៖

- ផ្ទៃដីទំហំ ១៩០,០១ ហិកតា កាត់ចេញពីព្រៃសម្បទានក្រុមហ៊ុន យូរីសាគរ សម្រាប់ធ្វើប្រទានកម្មទំហំ ១៥៩,៩៨ ហិកតា ជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ និងទំហំ ១៧,១១ ហិកតា សម្រាប់គោលដៅសម្បទានសេដ្ឋកិច្ចខ្នាតតូច ហើយទំហំ ១២,៩២ ហិកតា រក្សាទុកជាដីសាធារណៈរបស់រដ្ឋ នៅភូមិផ្ទះរុង

- កាត់ផ្ទៃដីទំហំ ៤៤២,៨៥ ហិកតា ក្នុងនោះ ទំហំ ៤០២,៨៥ ហិកតា កាត់ចេញពីគម្រប ព្រៃឈើឆ្នាំ ២០០២ និងទំហំ ៤០ ហិកតា កាត់ចេញព្រៃសម្បទានក្រុមហ៊ុន

យូរីសាគរ សម្រាប់ធ្វើប្រទានកម្មទំហំ ៣៥៩,៦៧ ហិកតា ជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ និងទំហំ ៨៨,៦២ ហិកតា សម្រាប់គោលដៅសម្បទានសេដ្ឋកិច្ចខ្នាតតូច ហើយទំហំ ៣៨,៥៦ ហិកតា រក្សាទុកជាដីសាធារណៈរបស់រដ្ឋ នៅភូមិព្រហស្បត៏ក្បាល

- ផ្ទៃដីទំហំ ៣៥១,៩៥ ហិកតា កាត់ចេញពីព្រៃសម្បទានក្រុមហ៊ុន យូរីសាគរ សម្រាប់ធ្វើប្រទានកម្ម ទំហំ ៣២៨,៩៤ ហិកតា ជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ និងទំហំ ២៣,០១ ហិកតា រក្សាទុកជាដីសាធារណៈរបស់រដ្ឋ នៅភូមិជង្រុក

ចំណុចត្រៃទី១ ទី២ និងទី៣ តាមប្រព័ន្ធកូអរដោណេ Project UTM Zone 48N Datum WGS 1984 និងមាននិយាមកាដូចកំណត់ក្នុងផែនទីឧបសម្ព័ន្ធ (១) នៃអនុក្រឹត្យនេះ។

- កាត់ផ្ទៃដីទំហំ ២.៥៩២,៦៧ ហិកតា ក្នុងនោះ ទំហំ ១.០៤៩,៨៣ ហិកតា កាត់ចេញពីព្រៃសម្បទានក្រុមហ៊ុន យូរីសាគរ និងទំហំ ១.៥៤២,៨៤ ហិកតា កាត់ចេញពីដីរបស់ក្រុមហ៊ុន តូច ហ៊ារ អ៊ិនខូបរ៉េសិន សម្រាប់ធ្វើប្រទានកម្មទំហំ ១.៤៤៨,៨៦ ហិកតា ជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ និងទំហំ ១.០១៣,៥៦ ហិកតា សម្រាប់គោលដៅសម្បទានសេដ្ឋកិច្ចខ្នាតតូច ហើយទំហំ ១៣០,២៥ ហិកតា រក្សាទុកជាដីសាធារណៈរបស់រដ្ឋ នៅភូមិជ្រៃក្រឹម

តាមប្រព័ន្ធកូអរដោណេ Project UTM Zone 48N Datum WGS 1984 និងមាននិយាមកាដូចកំណត់ក្នុងផែនទីឧបសម្ព័ន្ធ (២) នៃអនុក្រឹត្យនេះ ។

មាត្រា ២.-

ត្រូវបានប្រគល់អាណត្តិកាន់កាប់ និងបែងចែកដីរបស់រដ្ឋដូចមានចែងក្នុងមាត្រា ១ ជូនគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តពោធិ៍សាត់ ធ្វើការគ្រប់គ្រង និងប្រទានកម្មជាកម្មសិទ្ធិឯកជនជូនប្រជាពលរដ្ឋ ចំនួន ៨៧៧ គ្រួសារ ដែលបានកាន់កាប់ ប្រើប្រាស់ និងដាំដុះជាក់ស្តែង នៅឃុំផ្ទះរុង ស្រុកភ្នំក្រវ៉ាញ ខេត្តពោធិ៍សាត់ ដែលស្ថិតក្នុងភូមិ ដូចខាងក្រោម ៖

- ប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ ៦៤ គ្រួសារ និងសម្រាប់គោលដៅសម្បទានសេដ្ឋកិច្ចខ្នាតតូច នៅភូមិផ្ទះរុង
- ប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ ២២៧ គ្រួសារ និងសម្រាប់គោលដៅសម្បទានសេដ្ឋកិច្ចខ្នាតតូច នៅភូមិព្រហស្បត៏ក្បាល
- ប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ ១៣០ គ្រួសារ នៅភូមិជង្រុក
- ប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ ៤៥៦ គ្រួសារ និងសម្រាប់គោលដៅសម្បទានសេដ្ឋកិច្ចខ្នាតតូចនៅភូមិជ្រៃក្រឹម។

មាត្រា ៣.-

ក្នុងពេលដំណើរការវាស់វែង និងបែងចែកជាក់ស្តែង គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តពោធិ៍សាត់ ត្រូវកាត់ចេញនូវចំណែកដីមួយចំនួនសមស្រប ដើម្បីរក្សាទុកសម្រាប់បម្រើផលប្រយោជន៍សាធារណៈ ជាអាទិ៍ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវន្ត និងសង្គម នៅក្នុងមូលដ្ឋាន ។

មាត្រា ៤.-

បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយពីអនុក្រឹត្យនេះត្រូវចាត់ទុកជានិរាករណ៍ ។

មាត្រា ៥.-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រីក្រសួងបរិស្ថាន រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ និងអភិបាលនៃគណៈអភិបាលខេត្តពោធិ៍សាត់ ត្រូវអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែ មិនា ឆ្នាំ២០១៣

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល៖

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការ រាជរដ្ឋាភិបាល*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា*
- *អគ្គលេខាធិការដ្ឋានអាជ្ញាធរជាតិដោះស្រាយវិវាទដីធ្លី*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ៥*
- *រាជកិច្ច*
- *ឯកសារកាលប្បវត្តិ*

ឧបសម្ព័ន្ធ(១)នៃអនុក្រឹត្យលេខ ...១៣... ចុះថ្ងៃទី .... ខែ .... ឆ្នាំ ២០១៣ ស្តីពីការកាត់ដីសម្បទានទំហំ ៣..៥៧៧,៤៨ ហិកតា នៅស្រុកក្រគរ ខេត្តពោធិ៍សាត់ ក្នុងនោះ កាត់ចេញពីគម្របព្រៃឈើឆ្នាំ ២០០២ កាត់ចេញពីព្រៃសម្បទានក្រុមហ៊ុន យូរីសោគរ និងកាត់ពីដីរបស់ក្រុមហ៊ុន តួច ហ៊ាង អ៊ិនខុបរ៉េសិន និងធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋសម្រាប់ធ្វើប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ ៨៧៧ គ្រួសារ និងរក្សាទុកមួយចំណែកជាដីសាធារណៈរបស់រដ្ឋ



តារាងនិយាមការចំណុចព្រំដី

Prjection UTM, Zone 48N, Datum WGS 84

P_ID	X	Y	P_ID	X	Y
1	357645	1372505	44	359068	1369688
2	358643	1370318	45	358493	1369344
3	360309	1368834	46	358457	1369279
4	360541	1368471	47	358394	1369269
5	360662	1368128	48	358321	1369145
6	360851	1367070	49	358230	1369180
7	360515	1367070	50	358123	1368976
8	359842	1367155	51	357556	1369211
9	359869	1367338	52	357709	1370394
10	359555	1367340	53	357200	1370282
11	359563	1367458	54	357098	1370318
12	359491	1367467	55	356971	1370214
13	359513	1367572	56	356940	1370226
14	359357	1367603	57	356762	1370208
15	359391	1367703	58	356575	1370332
16	359489	1367695	59	356453	1370331
17	359487	1367779	60	356152	1370340
18	359447	1367835	61	355807	1370338
19	359349	1367832	62	355700	1370333
20	359297	1367815	63	355624	1370325
21	359234	1367805	64	355590	1370324
22	359052	1367839	65	355331	1370452
23	359007	1367834	66	355108	1370765
24	358864	1367854	67	355089	1370816
25	358860	1367868	68	355141	1370838
26	358833	1367910	69	355282	1371016
27	358836	1367948	70	355332	1371059
28	358838	1367872	71	355385	1371091
29	358878	1367962	72	355400	1371157
30	358888	1368004	73	355451	1371257
31	358810	1368046	74	355505	1371242
32	358831	1368221	75	355511	1371261
33	358329	1368331	76	355550	1371256
34	358363	1368434	77	356116	1371647
35	358512	1368679	78	356231	1371813
36	358725	1368855	79	356668	1372000
37	359039	1368854	80	356832	1372372
38	359149	1368915	81	356884	1372522
39	359076	1369097	82	356894	1372525
40	359203	1369164	83	356938	1372526
41	359216	1369173	84	356968	1372636
42	359052	1369245	85	357068	1372605
43	359234	1369536	86	357122	1372693

ឧបសម្ព័ន្ធ(២)នៃអនុក្រឹត្យលេខ [illegible] ចុះថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ ២០១៣ ស្តីពីការកាត់ដីសរុប ទំហំ ៣.៥៧៧,៤៩ ហិកតា នៅស្រុកក្រគរ ខេត្តពោធិ៍សាត់ ក្នុងនោះ កាត់ចេញពីតំបន់ព្រៃឈើឆ្នាំ ២០០២ កាត់ចេញពីព្រៃសម្បទាន ក្រុមហ៊ុន ឃុំសោគ និងកាត់ញពីដីរបស់ក្រុមហ៊ុន គុច ហ៊ាង អ៊ិនខ្មែរស៊ិន និងធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋសម្រាប់ធ្វើចម្ការកម្ម ជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ ៨៧៧ គ្រួសារ និងរក្សាទុកមួយចំណែកជាដីសាធារណៈរបស់រដ្ឋ



តារាងនិយាមការចំណុចព្រំដី

Prjection UTM, Zone 48N, Datum WGS 84

P_ID	X	Y	P_ID	X	Y	P_ID	X	Y
1	357122	1372693	35	352023	1368609	69	349636	1371545
2	357068	1372605	36	352130	1368625	70	350139	1371778
3	356968	1372636	37	352132	1368583	71	350412	1371306
4	356938	1372526	38	352202	1368633	72	350444	1371304
5	356894	1372525	39	352487	1368704	73	350434	1371414
6	356884	1372522	40	352512	1368644	74	350459	1371481
7	356668	1372000	41	352406	1368608	75	350448	1371533
8	356231	1371813	42	352339	1368489	76	350401	1371588
9	356116	1371647	43	351790	1368466	77	350430	1371645
10	355550	1371256	44	351746	1367466	78	350508	1371617
11	355511	1371261	45	351384	1367354	79	350560	1371517
12	355505	1371242	46	351073	1367192	80	350530	1371388
13	355451	1371257	47	350739	1367151	81	350672	1371373
14	355400	1371157	48	349924	1367348	82	350661	1371273
15	355385	1371091	49	349924	1367549	83	350848	1371208
16	355332	1371059	50	349483	1367609	84	350795	1371073
17	355282	1371016	51	349445	1368256	85	351407	1370937
18	355141	1370838	52	348856	1368193	86	351323	1370405
19	355089	1370816	53	348368	1368238	87	351121	1370432
20	354792	1370725	54	348193	1368375	88	351163	1370148
21	353589	1371343	55	347746	1368472	89	351134	1370049
22	353648	1369355	56	347812	1368892	90	351468	1370158
23	353308	1369378	57	346811	[illegible]	91	351545	1370139
24	353335	1369498	58	346821	[illegible]	92	351858	1370237
25	353219	1369521	59	347163	[illegible]	93	351941	1370636
26	353218	1369662	60	347432	1370506	94	352076	1370824
27	353107	1369669	61	349181	[illegible]	95	352520	1370948
28	353088	1369489	62	[illegible]	[illegible]	96	352639	1371260
29	352000	1369556	63	[illegible]	[illegible]	97	[illegible]	1371385
30	351957	1369221	64	349489	[illegible]	98	352479	1371853
31	351831	1368892	65	349671	[illegible]	99	[illegible]	1371941
32	351910	1368896	66	349691	1371135	100	[illegible]	1372147
33	351897	1368566	67	349615	1371174	101	352750	1372988
34	352024	1368574	68	349675	1371459	102	354219	1373656

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ១៤៤ អនក្រ.បក

អនុក្រឹត្យ

ស្តីពី

ការកាត់ដីទំហំ ៣០០,២៦៨៦ ហិកតា នៅស្រុកអូរជុំ ខេត្តរតនគិរី ចេញពីដីសម្បទានសេដ្ឋកិច្ចរបស់ក្រុមហ៊ុន ស៊ី អ ឌី សម្រាប់ធ្វើប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ ៧៩ គ្រួសារ និងរក្សាទុកមួយចំណែកសម្រាប់កំណើនប្រជាពលរដ្ឋ និងហេដ្ឋារចនាសម្ព័ន្ធរូបវន្ត និងផ្តល់សិទ្ធិជាកម្មសិទ្ធិលើក្បាលដី

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២នសចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ១៩៩៩ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១ ដែលប្រកាសឲ្យប្រើច្បាប់ភូមិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០២/០១៦ ចុះថ្ងៃទី៣១ ខែសីហា ឆ្នាំ២០០២ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីព្រៃឈើ

- បានឃើញព្រះរាជក្រឹត្យលេខនស/រកត/០៨០៦/៣៣៩ ចុះថ្ងៃទី០៣ ខែសីហា ឆ្នាំ២០០៦ ស្តីពីគោលការណ៍ និងបញ្ញត្តិអន្តរកាលនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋនិងរបស់នីតិបុគ្គលសាធារណៈ
- បានឃើញអនុក្រឹត្យលេខ៦២ អនក្រ.បក ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញអនុក្រឹត្យលេខ១៧ អនក្រ.បក ចុះថ្ងៃទី០៧ ខែមេសា ឆ្នាំ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ៨៨ អនក្រ.បក ចុះថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០០០ ស្តីពីការបង្កើតក្រុមប្រឹក្សាគោលនយោបាយដីធ្លី
- បានឃើញអនុក្រឹត្យលេខ១១៨ អនក្រ.បក ចុះថ្ងៃទី០៧ ខែតុលា ឆ្នាំ២០០៥ ស្តីពីការគ្រប់គ្រងដីរដ្ឋ
- បានឃើញអនុក្រឹត្យលេខ១៤៦ អនក្រ.បកចុះថ្ងៃទី២៧ខែធ្នូ ឆ្នាំ២០០៥ ស្តីពីសម្បទានដីសេដ្ឋកិច្ច
- បានឃើញសារាចរលេខ ០២ សរ ចុះថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០០៧ ស្តីពីការកាន់កាប់ដីរដ្ឋដោយខុសច្បាប់
- លិខិតលេខ ០៩៥/១៣ ចុះថ្ងៃទី ០១ ខែ មិនា ឆ្នាំ២០១៣ របស់គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តរតនគិរី
- យោងតាមការចាំបាច់របស់រាជរដ្ឋាភិបាល

សម្រេច

មាត្រា ១.-

ត្រូវបានកាត់ដីទំហំ ៣០០,២៦៨៦ ហិកតា ចេញពីដីសម្បទានសេដ្ឋកិច្ចរបស់ក្រុមហ៊ុន ស៊ី អ ឌី សម្រាប់ធ្វើប្រទានកម្ម ទំហំ ២៦៥,៦៣៧៩ ហិកតា ជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ និងទំហំ ៣៤,៦៣០៧ ហិកតា រក្សាទុកសម្រាប់កំណើនប្រជាពលរដ្ឋ និងហេដ្ឋារចនាសម្ព័ន្ធរូបវន្ត នៅភូមិពីង ឃុំសាមគ្គី ស្រុកអូរជុំ ខេត្តរតនគិរី តាមប្រព័ន្ធកូអរដោណេ Project UTM Zone 48N Datum wgs 1984 និងមាននិយាមកាដូចកំណត់ក្នុងផែនទីឧបសម្ព័ន្ធនៃអនុក្រឹត្យនេះ។

មាត្រា ២.-

ត្រូវបានប្រគល់អាណត្តិកាន់កាប់ និងបែងចែកដីឯកជនរបស់រដ្ឋដូចមានចែងក្នុងមាត្រា១ ជូនគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តរតនគិរី ដើម្បីធ្វើការគ្រប់គ្រង និងប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ ៧៩ គ្រួសារ ដែលបានកាន់កាប់ ប្រើប្រាស់ និងដាំដុះដាក់ស្តែង នៅភូមិពីង ឃុំសាមគ្គី ស្រុកអូរជុំ ខេត្តរតនគិរី ។

មាត្រា ៣.-

ត្រូវបានផ្តល់សិទ្ធិជាកម្មសិទ្ធិឯកជនលើក្បាលដីចំនួន ១១០ ក្បាលដី ជូនប្រជាពលរដ្ឋ ៧៧ គ្រួសារ នៅភូមិពីង ឃុំសាមគ្គី ស្រុកអូរជុំ ខេត្តរតនគិរី ។

មាត្រា ៤.-

ក្នុងពេលដំណើរការវាស់វែង និងបែងចែកជាក់ស្តែង គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តរតនគិរី ត្រូវកាត់ចេញនូវចំណែកដីមួយចំនួនសមស្រប ដើម្បីរក្សាទុកសម្រាប់បម្រើផលប្រយោជន៍សាធារណៈ ជាអាទិ៍ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវន្ត និងសង្គម នៅក្នុងមូលដ្ឋាន ។

មាត្រា ៥.-

បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយពីអនុក្រឹត្យនេះត្រូវចាត់ទុកជានិរាករណ៍ ។

មាត្រា ៦.-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រីក្រសួងបរិស្ថាន រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ និងអភិបាលនៃគណៈអភិបាលខេត្តរតនគិរី ត្រូវអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី០៧ ខែ [illegible] ឆ្នាំ ២០១៣

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល៖

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការ រាជរដ្ឋាភិបាល*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា*
- *អគ្គលេខាធិការដ្ឋានអាជ្ញាធរជាតិដោះស្រាយវិវាទដីធ្លី*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ៦*
- *រាជកិច្ច*
- *ឯកសារកាលប្បវត្តិ*

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៧៥ អនក្រ.បក

អនុក្រឹត្យ

ស្តីពី

ការកាត់ដីសរុបទំហំ ១៣០០,០២៦៧ ហិកតា នៅស្រុកអណ្តូងមាស ខេត្តរតនគិរី ចេញពីដីសម្បទានសេដ្ឋកិច្ចរបស់ក្រុមហ៊ុន ទាសនា អិនវេសមេន សម្រាប់ធ្វើប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ ៧៨ គ្រួសារ និងរក្សាទុកមួយចំណែកសម្រាប់កំណើនប្រជាពលរដ្ឋ និងហេដ្ឋារចនាសម្ព័ន្ធរូបវន្ត និងផ្តល់សិទ្ធិជាកម្មសិទ្ធិលើក្បាលដី

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២នសចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ១៩៩៩ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១ ដែលប្រកាសឲ្យប្រើច្បាប់ភូមិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០២/០១៦ ចុះថ្ងៃទី៣១ ខែសីហា ឆ្នាំ២០០២ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីព្រៃឈើ

- បានឃើញព្រះរាជក្រឹត្យលេខនស/រកត/០៨០៦/៣៣៩ ចុះថ្ងៃទី០៣ ខែសីហា ឆ្នាំ២០០៦ ស្តីពីគោលការណ៍ និងបញ្ញត្តិអន្តរកាលនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋនិងរបស់នីតិបុគ្គលសាធារណៈ
- បានឃើញអនុក្រឹត្យលេខ៦២ អនក្រ.បក ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញអនុក្រឹត្យលេខ១៧ អនក្រ.បក ចុះថ្ងៃទី០៧ ខែមេសា ឆ្នាំ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ៨៨ អនក្រ.បក ចុះថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០០០ ស្តីពីការបង្កើតក្រុមប្រឹក្សាគោលនយោបាយដីធ្លី
- បានឃើញអនុក្រឹត្យលេខ១១៨ អនក្រ.បក ចុះថ្ងៃទី០៧ ខែតុលា ឆ្នាំ២០០៥ ស្តីពីការគ្រប់គ្រងដីរដ្ឋ
- បានឃើញអនុក្រឹត្យលេខ១៤៦ អនក្រ.បកចុះថ្ងៃទី២៧ខែធ្នូ ឆ្នាំ២០០៥ ស្តីពីសម្បទានដីសេដ្ឋកិច្ច
- បានឃើញសារាចរលេខ ០២ សរ ចុះថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០០៧ ស្តីពីការកាន់កាប់ដីរដ្ឋដោយខុសច្បាប់
- លិខិតលេខ ០៩៧/១៣ ចុះថ្ងៃទី ០១ ខែ មិនា ឆ្នាំ២០១៣ របស់គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តរតនគិរី
- យោងតាមការចាំបាច់របស់រាជរដ្ឋាភិបាល

សម្រេច

មាត្រា ១.-

ត្រូវបានកាត់ផ្ទៃដីទំហំ ១៣០០,០២៦៧ ហិកតា ចេញពីដី សម្បទានសេដ្ឋកិច្ចរបស់ក្រុមហ៊ុន វាសនាអិនវេសមេន សម្រាប់ធ្វើប្រទានកម្មទំហំ ១.០៩៥,០២២៦ ហិកតា ជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ និងទំហំ ២០៥,០០៤១ ហិកតា រក្សាទុកសម្រាប់កំណើនប្រជាពលរដ្ឋ និងហេដ្ឋារចនាសម្ព័ន្ធរូបវន្ត នៅភូមិកាតែ ឃុំម៉ាលិក ស្រុកអណ្តូងមាស ខេត្តរតនគិរី តាមប្រព័ន្ធកូអរដោណេ Project UTM Zone 48N Datum wgs 1984 និងមាននិយាមកាដូចកំណត់ក្នុងផែនទីឧបសម្ព័ន្ធនៃអនុក្រឹត្យនេះ។

មាត្រា ២.-

ត្រូវបានប្រគល់អាណត្តិកាន់កាប់ និងបែងចែកដីឯកជនរបស់រដ្ឋដូចមានចែងក្នុងមាត្រា១ ជូនគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តរតនគិរី ដើម្បីធ្វើការគ្រប់គ្រង និងប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ ៧៨ គ្រួសារ ដែលបានកាន់កាប់ ប្រើប្រាស់ និងដាំដុះដាក់ស្តែង នៅភូមិកាតែ ឃុំម៉ាលិក ស្រុកអណ្តូងមាស ខេត្តរតនគិរី។

មាត្រា ៣.-

ត្រូវបានផ្តល់សិទ្ធិជាកម្មសិទ្ធិឯកជនលើក្បាលដីចំនួន ៨៤ ក្បាលដី ជូនប្រជាពលរដ្ឋ ៤៩ គ្រួសារ នៅភូមិកាតែ ឃុំម៉ាលិក ស្រុកអណ្តូងមាស ខេត្តរតនគិរី ។

មាត្រា ៤.-

Phone : 855-23-724 664 Fax : 855-23-427 798

- បានឃើញអនុក្រឹត្យលេខ ៨២ អនក្រ.បក ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៥ ស្តីពីបទបញ្ជាទូទៅនៃគណនេយ្យសាធារណៈ
- បានឃើញបទបញ្ជាលេខ ០៤ បប. ចុះថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០០៦ របស់រាជរដ្ឋាភិបាល ស្តីពីការពង្រឹងការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ
- យោងប្រកាសរួមលេខ ៩៩៩ សហវ. ប្រក ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០១២ ស្តីពីការផ្តល់សេវាសាធារណៈរបស់ក្រសួងបរិស្ថាន

សម្រេច

ប្រការ ១ :

ត្រូវបានផ្តល់ប្រាក់រង្វាន់លើកទឹកចិត្ត ជូនក្រសួងបរិស្ថាន និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សម្រាប់ឧបត្ថម្ភជូនមន្ត្រីដែលបំពេញភារកិច្ចផ្ទាល់ និងមន្ត្រីផ្សេងៗទៀត លើការបម្រើសេវាសាធារណៈ ព្រមទាំងសម្រាប់ពង្រឹងយន្តការប្រមូលចំណូល។

ប្រការ ២ :

ការផ្តល់ប្រាក់រង្វាន់លើកទឹកចិត្តនេះ ត្រូវបានបែងចែកដាច់ដោយឡែកពីគ្នា រវាងរដ្ឋបាលកណ្តាល និងមន្ទីរជំនាញរាជធានី ខេត្ត នៃក្រសួងបរិស្ថាន និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដោយផ្អែកលើមូលដ្ឋាននៃការបែងចែកភារកិច្ចក្នុងការផ្តល់សេវាសាធារណៈ ដែលអនុវត្តដោយរដ្ឋបាលកណ្តាល និងការផ្តល់សេវាសាធារណៈដែលអនុវត្តដោយមន្ទីរជំនាញរាជធានី ខេត្ត។

ប្រការ ៣ :

អនុញ្ញាតឱ្យរដ្ឋបាលកណ្តាលនៃក្រសួងបរិស្ថាន និងមន្ទីរបរិស្ថានរាជធានី ខេត្ត កាត់ទុកជាមុននូវចំណែកប្រាក់រង្វាន់ ដោយដកយកពីប្រាក់ចំណូលដែលប្រមូលបានរៀងៗខ្លួនពីការផ្តល់សេវាសាធារណៈ ដូចបានកំណត់ដោយប្រកាសរួមលេខ ៩៩៩ សហវ. ប្រក ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០១២ ស្តីពីការផ្តល់សេវាសាធារណៈរបស់ក្រសួងបរិស្ថាន។ ការកាត់ទុកជាមុននូវចំណែកប្រាក់រង្វាន់នេះ ត្រូវបានចាត់ទុកថា ថវិកាជាតិបានបើកផ្តល់ជាប្រាក់បុរេប្រទានជូនរដ្ឋបាលកណ្តាលនៃក្រសួងបរិស្ថាន និងមន្ទីរបរិស្ថានរាជធានី ខេត្ត សម្រាប់ការចំណាយឧបត្ថម្ភជូនមន្ត្រី និងពង្រឹងយន្តការប្រមូលចំណូល ដែលបានកំណត់នៅក្នុងប្រការ១ នៃប្រកាសរួមនេះ។ ប្រាក់រង្វាន់ដែលអនុញ្ញាតឱ្យកាត់ទុកជាមុននេះ រួមមានចំណែកប្រាក់រង្វាន់របស់ក្រសួងបរិស្ថាន និងចំណែកប្រាក់រង្វាន់របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

ប្រការ ៤ :

ការផ្តល់ប្រាក់រង្វាន់ជូនក្រសួងបរិស្ថាន និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវបានកំណត់ជាសមាមាត្រភាគរយធៀបទៅនឹងប្រាក់ចំណូលប្រមូលបាន និងត្រូវបានបែងចែក ដូចខាងក្រោម ៖

ក. ការបែងចែកសម្រាប់រដ្ឋបាលកណ្តាល

- បង់ចូលថវិកាជាតិ តាមចំណែកដែលកំណត់ក្នុងតារាងឧបសម្ព័ន្ធ
- ជូនក្រសួងបរិស្ថាន តាមចំណែកដែលកំណត់ក្នុងតារាងឧបសម្ព័ន្ធ
- ជូនក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ តាមចំណែកដែលកំណត់ក្នុងតារាងឧបសម្ព័ន្ធ

ខ. ការបែងចែកសម្រាប់មន្ទីរជំនាញរាជធានី ខេត្ត

- បង់ចូលថវិកាជាតិ តាមចំណែកដែលកំណត់ក្នុងតារាងឧបសម្ព័ន្ធ
- ជូនមន្ទីរបរិស្ថានរាជធានី ខេត្ត តាមចំណែកដែលកំណត់ក្នុងតារាងឧបសម្ព័ន្ធ
- ជូនមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុរាជធានី ខេត្ត តាមចំណែកដែលកំណត់ក្នុងតារាងឧបសម្ព័ន្ធ

ប្រការ ៥ :

រដ្ឋបាលកណ្តាលនៃក្រសួងបរិស្ថាន និងមន្ទីរបរិស្ថានរាជធានី ខេត្ត ត្រូវគ្រោងចំណូល និងចំណាយដែលជាកម្មវត្ថុសម្រាប់ការផ្តល់ប្រាក់រង្វាន់លើកទឹកចិត្ត នៅក្នុងគម្រោងចំណូល និងចំណាយនៃថវិកាប្រចាំឆ្នាំរបស់ខ្លួនដោយឡែកពីគ្នា។ រដ្ឋបាលកណ្តាលនៃក្រសួងបរិស្ថាន ត្រូវគ្រោងឥណទានប្រាក់រង្វាន់ ដោយគិតបញ្ចូលរួមទាំងឥណទានសម្រាប់ការចំណាយលើប្រាក់រង្វាន់របស់រដ្ឋបាលកណ្តាលនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។ មន្ទីរបរិស្ថានរាជធានី ខេត្ត ត្រូវគ្រោងឥណទានប្រាក់រង្វាន់ ដោយគិតបញ្ចូលរួមទាំងឥណទានសម្រាប់ការចំណាយលើប្រាក់រង្វាន់របស់មន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុរាជធានី ខេត្ត។

រាល់ប្រតិបត្តិការនៃចំណូល និងចំណាយទាំងនេះ ត្រូវកត់ត្រាឆ្លុះបញ្ចាំងក្នុងថវិកាជាតិ ដូចប្រតិបត្តិការនៃចំណូល និងចំណាយដទៃទៀតរបស់រដ្ឋបាលកណ្តាល និងមន្ទីរជំនាញរាជធានី ខេត្ត នៃក្រសួងបរិស្ថានដែរ។ ឥណទានដែលបានគ្រោងសម្រាប់ការចំណាយលើប្រាក់រង្វាន់នេះ ជាកម្មវត្ថុនៃការធ្វើអាណត្តិបើកប្រាក់ ដើម្បីទូទាត់ជាមួយចំនួនទឹកប្រាក់ដែលចាត់ទុកថាបានបុរេប្រទានពីថវិកាជាតិ(ប្រាក់ចំណូលដែលបានកាត់ទុកជាមុន)។

ការកត់ត្រាចំណូល និងចំណាយក្នុងកិច្ចប្រតិបត្តិការថវិកាជាតិ លើការផ្តល់ប្រាក់រង្វាន់លើកទឹកចិត្ត ត្រូវអនុវត្តតាមនីតិវិធីទូទាត់ប្រាក់បុរេប្រទាន ដូចខាងក្រោម ៖

ក. ផ្នែកចំណូលៈត្រូវធ្វើសលាកប័ត្រចំណូលថវិកាជាតិ នូវចំនួនទឹកប្រាក់ដែលបានបុរេប្រទាន ៖

- ចំពោះរដ្ឋបាលកណ្តាលនៃក្រសួងបរិស្ថាន ត្រូវរៀបចំ និងបញ្ជូនសលាកប័ត្រចំណូលថវិកាជាតិ មកនាយកដ្ឋានចំណូលមិនមែនសារពើពន្ធ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដោយភ្ជាប់មកជាមួយនូវរបាយការណ៍ស្ថានភាព ស្តីពីការអនុវត្តចំណូល និងតារាង ស្តីពីការគណនាប្រាក់រង្វាន់ ព្រមទាំងរបាយការណ៍ ស្តីពីការបែងចែកប្រាក់រង្វាន់ដែលបានបើកផ្តល់កន្លងមក។ នាយកដ្ឋានចំណូលមិនមែនសារពើពន្ធ ត្រូវចេញលិខិតពិនិត្យបញ្ជាក់លើចំនួនទឹកប្រាក់ដែលបានចុះក្នុងសលាកប័ត្រ។
- ចំពោះមន្ទីរបរិស្ថានរាជធានី ខេត្ត ត្រូវរៀបចំ និងបញ្ជូនសលាកប័ត្រចំណូលថវិកាជាតិ មកមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុរាជធានី ខេត្ត ដោយភ្ជាប់មកជាមួយនូវរបាយការណ៍ស្ថានភាព ស្តីពីការអនុវត្តចំណូល និងតារាង ស្តីពីការគណនាប្រាក់រង្វាន់ ព្រមទាំងរបាយការណ៍ ស្តីពីការបែងចែកប្រាក់រង្វាន់ដែលបានបើកផ្តល់កន្លងមក។ មន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុរាជធានី ខេត្តត្រូវចេញលិខិតពិនិត្យបញ្ជាក់លើចំនួនទឹកប្រាក់ដែលបានចុះក្នុងសលាកប័ត្រ។

ខ. ផ្នែកចំណាយៈ ត្រូវធ្វើអាណត្តិបើកប្រាក់ ដោយចុះចំនួនទឹកប្រាក់ស្មើនឹងចំនួនទឹកប្រាក់បុរេប្រទានដែលបានចុះនៅក្នុងសលាកប័ត្រចំណូលថវិកាជាតិ។

ប្រការ ៦ :

ក្រោយពីបានបំពេញនីតិវិធី ដែលមានចែងក្នុងប្រការ ៥ ខាងលើ ការបើកផ្តល់ប្រាក់រង្វាន់លើកទឹកចិត្តត្រូវអនុវត្ត ដូចខាងក្រោម ៖

ក. ការបើកផ្តល់ប្រាក់រង្វាន់ជូនមន្ត្រីរាជការនៃក្រសួងបរិស្ថាន ត្រូវអនុលោមតាមការសម្រេចរបស់រដ្ឋមន្ត្រីក្រសួងបរិស្ថាន ដោយឈរលើគោលការណ៍សមធម៌ និងផ្អែកតាមគុណសម្បត្តិការងារ។

ខ. ការបើកផ្តល់ប្រាក់រង្វាន់ជូនមន្ត្រីរាជការនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវអនុលោមតាមការសម្រេចរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដោយឈរលើគោលការណ៍សមធម៌ និងផ្អែកតាមគុណសម្បត្តិការងារ។

ប្រការ ៧ :

បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងប្រកាសរួមនេះ ត្រូវចាត់ទុកជានិរាករណ៍។

ប្រការ ៨ :

អគ្គលេខាធិការ នាយកខុទ្ទកាល័យ អគ្គនាយក ប្រធាននាយកដ្ឋាន និងប្រធានអង្គភាពពាក់ព័ន្ធក្រោមឱវាទក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រោមឱវាទក្រសួងបរិស្ថាន ត្រូវទទួលបន្ទុកអនុវត្តប្រកាសរួមនេះ ឱ្យមានប្រសិទ្ធភាពខ្ពស់ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ឧបនាយករដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

គាត ឈន់

ទេសរដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងបរិស្ថាន

ម៉ុក_ម៉ារ៉េត
បណ្ឌិត.ជិវិទ្យា

ចម្លងជូន:

- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី
- អាជ្ញាធរសេវនកម្មជាតិ
- អង្គភាពប្រឆាំងអំពើពុករលួយ
- គ្រប់រដ្ឋបាលរាជធានី ខេត្ត

«ដើម្បីជូនជ្រាប»

- ដូចប្រការ ៨ **«ដើម្បីមុខការ»**
- ឯកសារ - កាលប្បវត្តិ

តារាងឧបសម្ព័ន្ធ

ភ្ជាប់នឹងប្រកាសរួមលេខ ១០០០ សហវ.ប្រក ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០១២

ស្តីពីការផ្តល់ទ្រៅន់លើកទឹកចិត្ត ជូនក្រសួងបរិស្ថាន(ក. បស្ថ) និង ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ(ក. សហវ)

ល.រ	បរិយាយ	អត្រាបែងចែក		
		ថវិកាជាតិ	ក. បស្ថ	ក. សហវ
I. **តម្លៃសេវានានាដែលពាក់ព័ន្ធដល់តំបន់ការពារធម្មជាតិ**				
1. ប្រាក់ពិន័យបទល្មើសធនធានធម្មជាតិ				
1.1	បទល្មើសធនធានធម្មជាតិថ្នាក់ទី 1	50%	49%	1%
1.2	បទល្មើសធនធានធម្មជាតិថ្នាក់ទី 2	50%	49%	1%
1.3	បទល្មើសធនធានធម្មជាតិថ្នាក់ទី 3	50%	49%	1%
1.4	បទល្មើសធនធានធម្មជាតិថ្នាក់ទី 4	50%	49%	1%
1.5	ប្រាក់ពិន័យតាមសាលក្រម ឬ សាលដីកាតុលាការ	75%	24%	1%
1.6	ប្រាក់លក់ឡាយឡុងពីវត្ថុចាប់យក រឹបអូសជាទ្រព្យសម្បត្តិរដ្ឋ	តាមការសម្រេចរបស់រដ្ឋមន្ត្រីក. សហវ ផ្អែកតាមការស្នើសុំពីរដ្ឋមន្ត្រី ក. បស្ថ	តាមការសម្រេចរបស់រដ្ឋមន្ត្រីក. សហវ ផ្អែកតាមការស្នើសុំពីរដ្ឋមន្ត្រី ក. បស្ថ	តាមការសម្រេចរបស់រដ្ឋមន្ត្រីក. សហវ ផ្អែកតាមការស្នើសុំពីរដ្ឋមន្ត្រី ក. បស្ថ
2. ថ្លៃឈ្នួលដីសម្បទាន				
2.1	ថវិកាមូលនិធិតំបន់ការពារធម្មជាតិ (បានមកពីការស្ម័គ្រចិត្តរបស់អតិថិជន) (គិត 1ហិចតា)	100%	0%	0%

ល.រ	បរិយាយ	អត្រាបែងចែក		
		ថវិកាជាតិ	ក. បស្ថ	ក. សហវ
3. ថ្លៃសួយសារឈើឈរ និងបុព្វលាភ (តំបន់ការពារធម្មជាតិគ្រប់គ្រងដោយក្រសួងបរិស្ថាន)				
3.1	ឈើប្រភេទប្រណិត			
3.1.1	កូនឈើដែលមានអង្កត់ផ្ចិតទំហំគល់តូចជាង 15សម (គិត 1ដើម)	100%	0%	0%
3.1.2	ឈើមូលដែលមានអង្កត់ផ្ចិតទំហំគល់ពី15-30 សម (គិត $1m^3$)	100%	0%	0%
	ក- ប្រភេទក្រញូង (គិត $1m^3$)	100%	0%	0%
	ខ- ប្រភេទនាងនួន (គិត $1m^3$)	100%	0%	0%
	គ- ប្រភេទបេង (គិត $1m^3$)	100%	0%	0%
3.1.3	ឈើមូលដែលមានអង្កត់ផ្ចិតទំហំគល់ធំជាង30សម(គិត 1m3)	100%	0%	0%
	ក- ប្រភេទក្រញូង (គិត $1m^3$)	100%	0%	0%
	ខ- ប្រភេទនាងនួន (គិត $1m^3$)	100%	0%	0%
	គ- ប្រភេទបេង (គិត $1m^3$)	100%	0%	0%
3.2	ឈើប្រភេទលេខ 1			
	- កូនឈើដែលមានអង្កត់ផ្ចិតទំហំគល់ពី15សម-30សម (គិត 1ដើម)	100%	0%	0%
	- ឈើមូលដែលមានអង្កត់ផ្ចិតទំហំគល់ធំជាង 30សម(គិត $1m^3$)	100%	0%	0%
3.3	ឈើប្រភេទលេខ 2			
	- កូនឈើដែលមានអង្កត់ផ្ចិតទំហំគល់ពី15សម-30សម(គិត 1ដើម)	100%	0%	0%
	- ឈើមូលដែលមានអង្កត់ផ្ចិតទំហំគល់ធំជាង30សម(គិត $1m^3$)	100%	0%	0%

ល.រ	បរិយាយ	អត្រាបែងចែក		
		ថវិកាជាតិ	ក. បស្ថ	ក. សហវ
3.4	ឈើប្រភេទលេខ3 និងក្រៅលំដាប់ថ្នាក់			
	- កូនឈើដែលមានអង្កត់ផ្ចិតទំហំគល់ពី15សម-30សម(គិត 1ដើម)	100%	0%	0%
	- ឈើមូលដែលមានអង្កត់ផ្ចិតទំហំគល់ធំជាង30សម (គិត $1m^3$)	100%	0%	0%
3.5	កូនឈើចម្រុះ(លើកលែងប្រណីត)ដែលមានអង្កត់ផ្ចិតទំហំគល់តូចជាង 15សម (គិត 1ដើម)	100%	0%	0%
3.6	អុសចម្រុះ (ប្រើប្រាស់ជាថាមពល និង ធ្យូង)(គិត 1ស្ទែរ)	100%	0%	0%
II.	**ការកំណត់ថ្លៃសេវាសម្រាប់ការពិនិត្យរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងការតាមដានឃ្លាំមើលការអនុវត្តន៍គម្រោង**			
ក. វិស័យឧស្សាហកម្ម				
1	រោងចក្រកែច្នៃម្ហូបអាហារ និងគ្រឿងកំប៉ុង (គ្រប់ទំហំ)	70%	29%	1%
2	រោងចក្រផលិតភេសជ្ជៈ ទឹកផ្លែឈើគ្រប់ប្រភេទ	70%	29%	1%
3	រោងចក្រផលិតដំណាប់ផ្លែឈើ (គ្រប់ទំហំ)	70%	29%	1%
4	រោងចក្រផលិតទឹកក្រូច (គ្រប់ទំហំ)	70%	29%	1%
5	រោងចក្រផលិតស្រា (គ្រប់ទំហំ)	70%	29%	1%
6	រោងចក្រផលិតស្រាបៀរ អាល់កុល (គ្រប់ទំហំ)	70%	29%	1%
7	រោងចក្រផលិតទឹកស្អាត (≥10,000នាក់ប្រើប្រាស់)	70%	29%	1%
8	រោងចក្រផលិតបារី (≥10,000កញ្ចប់/ថ្ងៃ)	70%	29%	1%
9	រោងចក្រផលិតកែច្នៃសន្លឹកថ្នាំជក់ (គ្រប់ទំហំ)	70%	29%	1%
10	រោងចក្រផលិតស្ករស (គ្រប់ទំហំ)	70%	29%	1%
11	រោងចក្រកិនស្រូវ និងគ្រាប់ធញ្ញជាតិ (≥3,000តោន/ឆ្នាំ)	70%	29%	1%

ល.រ	បរិយាយ	អត្រាបែងចែក		
		ថវិកាជាតិ	ក. បស្ថ	ក. សហវ
12	រោងចក្រផលិតទឹកត្រី ស៊ីអ៊ីវ សៀង ម្ទេស ប៉េងប៉ោះ (គ្រប់ទំហំ)	70%	29%	1%
13	រោងចក្រតម្បាញ ជ្រលក់ពណ៌ (គ្រប់ទំហំ)	70%	29%	1%
14	រោងចក្រកាត់ដេរ បោកគក់ បោះពុម្ព ជ្រលក់ពណ៌ (គ្រប់ទំហំ)	70%	29%	1%
15	រោងចក្រសម្លាប់ស្បែក កែច្នៃស្បែក ធ្វើការស្បែកក្របី (គ្រប់ទំហំ)	70%	29%	1%
16	រោងចក្រផលិតអេប៉ុង កៅស៊ូមូស (គ្រប់ទំហំ)	70%	29%	1%
17	រោងចក្រក្តារបន្ទះ (>100,000ម^3/ឆ្នាំ-ឈើមូល)	70%	29%	1%
18	មូលដ្ឋានផលិតគ្រឿងសង្ហារឹម (>1,000ម^3/ឆ្នាំ ឈើមូល)	70%	29%	1%
19	រោងចក្រអារឈើ (>50,000 ម^3/ឆ្នាំ ឈើមូល)	70%	29%	1%
20	រោងចក្រផលិតក្រដាស (គ្រប់ទំហំ)	70%	29%	1%
21	រោងចក្រផលិតម្សៅក្រដាស និងកែច្នៃក្រដាស (គ្រប់ទំហំ)	70%	29%	1%
22	រោងចក្រប្លាស្ទិក (គ្រប់ទំហំ)	70%	29%	1%
23	រោងចក្រកៅស៊ូកង់ និងពោះវៀនកង់គ្រប់ប្រភេទ (≥500តោន /ឆ្នាំ)	70%	29%	1%
24	រោងចក្រកៅស៊ូក្រែបតោន (>1,000តោន /ឆ្នាំ)	70%	29%	1%
25	រោងចក្រផលិតអាគុយ និងថ្មពិល (គ្រប់ទំហំ)	70%	29%	1%
26	រោងចក្រគីមី (គ្រប់ទំហំ)	70%	29%	1%
27	រោងចក្រផលិតជីគីមី(>10,000 តោន/ឆ្នាំ)	70%	29%	1%
28	រោងចក្រផលិតថ្នាំសម្លាប់សត្វល្អិត (គ្រប់ទំហំ)	70%	29%	1%
29	រោងចក្រផលិតថ្នាំលាបគ្រប់ប្រភេទ (គ្រប់ទំហំ)	70%	29%	1%

ល.រ	បរិយាយ	អត្រាបែងចែក		
		ថវិកាជាតិ	ក. បស្	ក. សហរ
30	រោងចក្រគីមីប្រេងកាត (គ្រប់ទំហំ)	70%	29%	1%
31	រោងចក្រផលិតម្សៅសាប៊ូ សាប៊ូដុំ សាប៊ូទឹក (គ្រប់ទំហំ)	70%	29%	1%
32	រោងចក្រស៊ីម៉ង់ត៍ (គ្រប់ទំហំ)	70%	29%	1%
33	រោងចក្រចម្រាញ់ប្រេងកាត (គ្រប់ទំហំ)	70%	29%	1%
34	រោងចក្រផលិតឧស្ម័ន (គ្រប់ទំហំ)	70%	29%	1%
35	សំណង់បង្ហូរប្រេង និងឧស្ម័ន (>2គ,ម)	70%	29%	1%
36	កន្លែងផ្ទុកប្រេងឥន្ធនៈសម្រាប់ចែកចាយ (>1,000,000លីត្រ)	70%	29%	1%
37	ស្ថានីយប្រេងឥន្ធនៈ (≥20,000លីត្រ)	70%	29%	1%
38	ការធ្វើអាជីវកម្មរ៉ែ (គ្រប់ទំហំ)	70%	29%	1%
39	រោងចក្រផលិតកែវ ដបគ្រប់ប្រភេទ (គ្រប់ទំហំ)	70%	29%	1%
40	មូលដ្ឋានផលិតឥដ្ឋក្បឿង (គ្រប់ទំហំ)	70%	29%	1%
41	មូលដ្ឋានផលិតឥដ្ឋក្រាល ឥដ្ឋការ៉ូ (>90,000ដុំ/ខែ)	70%	29%	1%
42	រោងចក្រផលិតថ្មស្អុយ (គ្រប់ទំហំ)	70%	29%	1%
43	មូលដ្ឋានផលិតគ្រឿងសំណង់បេតុង (≥900តោន/ខែ)	70%	29%	1%
44	រោងចក្រផលិតខ្លាញ់គោ ប្រេងម៉ាស៊ីន (គ្រប់ប្រភេទ)	70%	29%	1%
45	ការសិក្សាស្រាវជ្រាវអាជីវកម្មរ៉ែប្រេងកាត ការខួងសាកល្បង ការ ធ្វើឱ្យរញ្ជួយដី (គ្រប់ទំហំ)	70%	29%	1%
46	រោងចក្រផលិតគ្រឿងយន្ត (គ្រប់ទំហំ)	70%	29%	1%
47	រោងចក្រដំឡើងគ្រឿងយន្ត (គ្រប់ទំហំ)	70%	29%	1%

ល.រ	បរិយាយ	អត្រាបែងចែក		
		ថវិកាជាតិ	ក. បស្ក	ក. សហវ
48	សហគ្រាសជួសជុលគ្រឿងយន្ត និងនាវា (គ្រប់ទំហំ)	70%	29%	1%
49	រោងចក្រកែច្នៃលោហៈគ្រប់ប្រភេទ ដែកគោល លួស បន្លា សំណាញ់ (≥300 តោន/ខែ)	70%	29%	1%
50	រោងចក្រស្លដែក ដែកថែប អាលុយមីញ៉ូម (គ្រប់ទំហំ)	70%	29%	1%
51	រោងចក្រស្លលោហៈគ្រប់ប្រភេទ (គ្រប់ទំហំ)	70%	29%	1%
52	រោងចក្រកែច្នៃសំណល់ ដុតសំណល់ (គ្រប់ទំហំ)	70%	29%	1%
53	មូលដ្ឋានសំអាតទឹកសំអុយ (គ្រប់ទំហំ)	70%	29%	1%
54	រោងចក្រអគ្គីសនី (≥5មេកាវ៉ាត់)	70%	29%	1%
55	រោងចក្រវារីអគ្គីសនី (≥1មេកាវ៉ាត់)	70%	29%	1%
56	រោងចក្រផលិតសំឡី (≥15តោន/ខែ)	70%	29%	1%
57	រោងចក្រផលិតចំណីសត្វ (>10,000តោន /ឆ្នាំ	70%	29%	1%
58	រោងចក្រកែច្នៃកម្ទេចប្លាស្ទីក និងផលិតផលពីប្លាស្ទីក (គ្រប់ប្រភេទ)	70%	29%	1%
59	រោងចក្រផលិតប្រេងម៉ាស៊ូតធម្មជាតិ (ពីល្ហុងខ្វង)(គ្រប់ប្រភេទ)	70%	29%	1%
60	រោងចក្រផលិត និងផ្គុំដំឡើងគ្រឿងម៉ាស៊ីន សម្ភារៈបរិក្ខារឧស្សាហកម្ម និងមុខសញ្ញាពាក់ព័ន្ធផ្សេងទៀត (គ្រប់ប្រភេទ)	70%	29%	1%
ខ. វិស័យសុខាភិបាល				
1	មន្ទីរពេទ្យ (គ្រប់ទំហំ)	70%	29%	1%
2	មន្ទីរពិសោធន៍ (គ្រប់ទំហំ)	70%	29%	1%

ល.រ	បរិយាយ	អត្រាបែងចែក		
		ថវិកាជាតិ	ក. បស្ក	ក. សហវ
3	រោងចក្រផលិតសម្ភារៈបរិក្ខារពេទ្យធ្មេញ (គ្រប់ទំហំ)	70%	29%	1%
4	រោងចក្រផលិតឱសថ (គ្រប់ទំហំ)	70%	29%	1%
5	រោងចក្រដំឡើងរថយន្តគិលានសង្គ្រោះ (គ្រប់ទំហំ)	70%	29%	1%
គ. វិស័យកសិកម្ម				
1	ព្រៃសម្បទាន (≥1,000ហិចតា) គិតក្នុង 1ហិចតា	70%	29%	1%
2	អាជីវកម្មព្រៃគប់ (≥500ហិចតា) គិតក្នុង 1ហិចតា	70%	29%	1%
3	ផ្ទៃដីដែលមានព្រៃឈើ(>500ហិចតា) គិតក្នុង 1ហិចតា	70%	29%	1%
4	ផ្ទៃដីដំណាំកសិកម្ម ឧស្សាហកម្ម (≥1,000ហិចតា) គិតក្នុង 1ហិចតា	70%	29%	1%
5	ផ្ទៃដីលិចទឹក និងដីតំបន់ឆ្នេរ (គ្រប់ទំហំ)	70%	29%	1%
6	ប្រព័ន្ធស្រោចស្រព (≥3,000ហិចតា)	70%	29%	1%
7	ប្រព័ន្ធដោះទឹក (≥3,000ហិចតា)	70%	29%	1%
8	ផែនេសាទ (គ្រប់ទំហំ)	70%	29%	1%
9	ស្តារ និងអភិវឌ្ឍន៍ដំណាំកសិឧស្សាហកម្ម (>500ហិចតា)	70%	29%	1%
10	កសិដ្ឋានចិញ្ចឹមសត្វគោ ក្របី (≥500ក្បាល)	70%	29%	1%
11	កសិដ្ឋានចិញ្ចឹមសត្វមាន់ ទា (≥10,000ក្បាល)	70%	29%	1%
12	កសិដ្ឋានចិញ្ចឹមសត្វជ្រូក (≥500ក្បាល)	70%	29%	1%
13	កសិដ្ឋានចិញ្ចឹមសត្វក្រពើ (≥500ក្បាល)	70%	29%	1%
14	វារីវប្បកម្មចិញ្ចឹមត្រី ក្តាម បង្គារ (≥10ហិចតា)	70%	29%	1%
15	វារីវប្បកម្មដាំសារាយ (≥20ហិចតា)	70%	29%	1%

ល.រ	បរិយាយ	អត្រាបែងចែក		
		ថវិកាជាតិ	ក. បស្ថ	ក. សហវ
ឃ. វិស័យទេសចរណ៍				
1	តំបន់ទេសចរណ៍ (≥50ហិចតា)	70%	29%	1%
2	ទីលានវាយកូនគោល (≥18 រន្ធ)	70%	29%	1%
3	ភោជនីយដ្ឋានបណ្តែតទឹក (≥300 កៅអី)	70%	29%	1%
4	បង្កើតសួនសត្វ(≥10ហិចតា)	70%	29%	1%
ង. ហេដ្ឋារចនាសម្ព័ន្ធ				
1	ការអភិវឌ្ឍន៍ទីក្រុង (គ្រប់ទំហំ)	70%	29%	1%
2	តំបន់ឧស្សាហកម្ម (គ្រប់ទំហំ)	70%	29%	1%
3	តំបន់ស្ពានថ្នល់ (ទ្រទំងន់≥30 តោន)	70%	29%	1%
4	សំណង់អាគារ (កំពស់>20ម ឬក្រឡាផ្ទៃ 8,000ម^2)	70%	29%	1%
5	ភោជនីយដ្ឋាន (≥500កៅអី)	70%	29%	1%
6	សំណង់សណ្ឋាគារ (≥60 បន្ទប់)	70%	29%	1%
7	សំណង់សណ្ឋាគារតំបន់ឆ្នេរ (≥ 40បន្ទប់)	70%	29%	1%
8	សំណង់ផ្លូវជាតិ (≥50 គ,ម)	70%	29%	1%
9	សំណង់ផ្លូវដែក (គ្រប់ទំហំ)	70%	29%	1%
10	សំណង់កំពង់ផែ (គ្រប់ទំហំ)	70%	29%	1%
11	សំណង់អាកាសយានដ្ឋាន (គ្រប់ទំហំ)	70%	29%	1%
12	ការបូមភក់ ល្បាប់ (≥ 50,000ម^3)	70%	29%	1%

ល.រ	បរិយាយ	អត្រាបែងចែក		
		ថវិកាជាតិ	ក. បស្ត	ក. សហវ
13	កន្លែងចាក់សំរាម (≥ប្រជាជន 200,000 នាក់)	70%	29%	1%
14	បណ្តាញខ្សែបញ្ជូនថាមពលអគ្គិសនី≥115KV	70%	29%	1%
15	សំណង់សណ្ឋាគារតាមមាត់ទន្លេ (≥ 80បន្ទប់)	70%	29%	1%
16	ការពង្រីកជួសជុលផ្លូវ ផ្លូវដែក (>=50គម)	70%	29%	1%
17	ការសាងសង់ពហុកីឡាដ្ឋាន (គ្រប់ទំហំ)	70%	29%	1%
18	នាវាចរណ៍ (≥100តោន)	70%	29%	1%
19	តំបន់សេដ្ឋកិច្ចពិសេស (គ្រប់ទំហំ)	70%	29%	1%
20	បណ្តាញខ្សែកាបអុបទិក	70%	29%	1%
21	សំណង់ផ្លូវនៅក្នុងតំបន់ការពារ (គ្រប់ទំហំ)	70%	29%	1%
ច. ប្រភេទគម្រោងដែលតម្រូវឱ្យធ្វើកិច្ចសន្យាការពារបរិស្ថាន				
1	ទីលានបញ្ចុះសព (≥5ហិចតា)	70%	29%	1%
2	រោងចក្រផលិតឆត្រ (គ្រប់ទំហំ)	70%	29%	1%
3	រោងចក្រផលិតស្ករគ្រាប់ (គ្រប់ទំហំ)	70%	29%	1%
4	រោងចក្រផលិតស្បែកជើង (គ្រប់ទំហំ)	70%	29%	1%
5	រោងចក្រផលិតកាបូបគ្រប់ប្រភេទ (គ្រប់ទំហំ)	70%	29%	1%
6	រោងចក្រផលិតសម្ភារៈកីឡា (គ្រប់ទំហំ)	70%	29%	1%
7	រោងចក្រផលិតពូក (គ្រប់ទំហំ)	70%	29%	1%
8	រោងចក្រផលិតកាបូប កន្សែង មុង និងតុក្កតា (គ្រប់ទំហំ)	70%	29%	1%

ល.រ	បរិយាយ	អត្រាបែងចែក		
		ថវិកាជាតិ	ក. បស្ត	ក. សហវ
9	រោងចក្រផលិតផលិតផលវេចខ្ចប់សម្រាប់នាំចេញ (គ្រប់ទំហំ)	70%	29%	1%
10	រោងចក្រផលិតស្រោមដៃ ស្រោមជើង កន្សែង មួក (គ្រប់ទំហំ)	70%	29%	1%
11	រោងចក្រផលិតខ្សែយឺតចង្កេះខោសម្រាប់ផ្គត់ផ្គង់ (គ្រប់ទំហំ)	70%	29%	1%
12	រោងចក្រផលិតកេសកាតុង (គ្រប់ទំហំ)	70%	29%	1%
13	រោងចក្រខារអំបោះដេរ និងផលិតស្កុតបិទ (គ្រប់ទំហំ)	70%	29%	1%
14	រោងចក្រផលិតសក់សិប្បនិម្មិត (គ្រប់ទំហំ)	70%	29%	1%
15	រោងចក្រផលិតទ្វារ និងកញ្ចក់ក្បាច់ (គ្រប់ទំហំ)	70%	29%	1%
16	រោងចក្រផលិតបន្ទះកម្រាល បន្ទះជញ្ជាំង បន្ទះហ្វីប្រូ និងក្បឿង (គ្រប់ទំហំ)	70%	29%	1%
17	ទីតាំងដំឡើងប្រព័ន្ធទូរស័ព្ទ (គ្រប់ទំហំ)	70%	29%	1%
18	រោងចក្រផលិតសម្ភារៈការិយាល័យគ្រប់ប្រភេទ (គ្រប់ទំហំ)	70%	29%	1%
19	រោងចក្រផលិតស័ង្កសី ទ្វាររមូល និងដែកសំណង់ (គ្រប់ទំហំ)	70%	29%	1%
20	រោងចក្រផលិតផ្លាកសញ្ញាសំលៀកបំពាក់ (គ្រប់ទំហំ)	70%	29%	1%
21	រោងចក្រផលិតម្សៅមី (គ្រប់ទំហំ)	70%	29%	1%
22	រោងចក្រផលិតទឹកតែត្រជាក់ (គ្រប់ទំហំ)	70%	29%	1%
23	រោងចក្រផលិតវត្ថុធាតុដើមសម្រាប់ផលិតឱសថ (គ្រប់ទំហំ)	70%	29%	1%
24	រោងចក្រផលិតក្រដាសអនាម័យ (គ្រប់ទំហំ)	70%	29%	1%
25	រោងចក្រផលិតសសរគ្រឹះ និងបង្គោលភ្លើង (គ្រប់ទំហំ)	70%	29%	1%
26	រោងចក្រផលិតសម្ភារៈបរិក្ខារអគ្គិសនី និងអេឡិចត្រូនិច (គ្រប់ទំហំ)	70%	29%	1%

ល.រ	បរិយាយ	អត្រាបែងចែក		
		ថវិកាជាតិ	ក. បស្ក	ក. សហវ
27	រោងចក្រផលិតដែក H និងសម្ភារៈផ្សេងៗ (គ្រប់ទំហំ)	70%	29%	1%
28	សិក្សាស្រាវជ្រាវរ៉ែ (គ្រប់ទំហំ)	70%	29%	1%
III. **សេវាមន្ទីរពិសោធន៍ និងសេវាផ្សេងៗ**				
ក-តម្លៃសេវាមន្ទីរពិសោធន៍				
1	Temperature	50%	49%	1%
2	PH	50%	49%	1%
3	Conductivity(EC)	50%	49%	1%
4	Turbidity	50%	49%	1%
5	Total Solid(TS)	50%	49%	1%
6	Total Dissolved Solid(TDS)	50%	49%	1%
7	Total Suspended Solid(TSS)	50%	49%	1%
8	Total Alkalinity(as CaCO3)	50%	49%	1%
9	Total Ha dness	50%	49%	1%
10	Dissolved Oxygen(DO)	50%	49%	1%
11	BOD	50%	49%	1%
12	COD	50%	49%	1%
13	Oil and Grease	50%	49%	1%
14	Phenol	50%	49%	1%

ល.រ	បរិយាយ	អត្រាបែងចែក		
		ថវិកាជាតិ	ក. បស្ថ	ក. សហវ
15	Cyanide(CN-)	50%	49%	1%
16	Fluo ide(F--)	50%	49%	1%
17	Dete gent(MBAS)	50%	49%	1%
18	Nitrogen Organic	50%	49%	1%
19	Ammonia(NH3)	50%	49%	1%
20	Nitrite(NO2)	50%	49%	1%
21	Nitrate(NO3)	50%	49%	1%
22	Total Phosphous (TP)	50%	49%	1%
23	Sulphate(SO4)	50%	49%	1%
24	Chloride(C1-)	50%	49%	1%
25	Manganese(Mn)	50%	49%	1%
26	Magnesium(Mg)	50%	49%	1%
27	Alumium	50%	49%	1%
28	Iron(Fe)	50%	49%	1%
29	Copper (Cu)	50%	49%	1%
30	Zinc(Zn)	50%	49%	1%
31	Cadmium(Cd)	50%	49%	1%
32	Selenium(Se)	50%	49%	1%

ល.រ	បរិយាយ	អត្រាបែងចែក		
		ថវិកាជាតិ	ក. បស្ថ	ក. សហវ
33	Mercury(Hg)	50%	49%	1%
34	Nickel(ni)	50%	49%	1%
35	Chromium(C)	50%	49%	1%
36	Lead(Pb)	50%	49%	1%
37	A senic(As)	50%	49%	1%
38	Total Coli form	50%	49%	1%
39	Feacal Coliform	50%	49%	1%
40	Total Bacteria	50%	49%	1%
41	Pathogen Staphylococcus	50%	49%	1%
42	E-Coli	50%	49%	1%
43	Feacal Streptococcus	50%	49%	1%
44	Total Nitrogen(TN)	50%	49%	1%
45	Thermo tolerant Coli form	50%	49%	1%
46	Barium(Ba)	50%	49%	1%
47	Beryllium(Be)	50%	49%	1%
48	Bismuth(Bi)	50%	49%	1%
49	Boron(B)	50%	49%	1%

ល.រ	បរិយាយ	អត្រាបែងចែក		
		ថវិកាជាតិ	ក. បស្ត	ក. សហវ
50	Calcium(Ca)	50%	49%	1%
51	Cobalt(Co)	50%	49%	1%
52	Cesium(Cs)	50%	49%	1%
53	Gallium(Ga)	50%	49%	1%
54	Indium(In)	50%	49%	1%
55	Potassium(k)	50%	49%	1%
56	Lithium(Li)	50%	49%	1%
57	Molybdenum(Mo)	50%	49%	1%
58	Rubidium(b)	50%	49%	1%
59	Sodium(Na)	50%	49%	1%
60	Silver(Ag)	50%	49%	1%
61	Strontium(S)	50%	49%	1%
62	Titanium(Ti)	50%	49%	1%
63	Vanadium(V)	50%	49%	1%
64	Uranium(U)	50%	49%	1%
65	Ortophosphate(PO4)	50%	49%	1%
66	Poliphosphate(PO4--)	50%	49%	1%
67	Carbondioxide(CO2)	50%	49%	1%

ល.រ	បរិយាយ	អត្រាបែងចែក		
		ថវិកាជាតិ	ក. បស្ថ	ក. សហវ
68	Salinity(NaC1)%	50%	49%	1%
69	Chromium(C 3)	50%	49%	1%
70	Chromium Exavalend(C 6)	50%	49%	1%
71	Sulphite(SO2)	50%	49%	1%
72	Sulfide(S)	50%	49%	1%
73	Brome(B)	50%	49%	1%
74	Iron(Fe+3)	50%	49%	1%
75	Iron(Fe+2)	50%	49%	1%
76	Color	50%	49%	1%
77	Chlorohpyll,a	50%	49%	1%
78	Transparency	50%	49%	1%
79	Ammonium(NH4)	50%	49%	1%
80	HydrogenCarbonate(HCO3)	50%	49%	1%
81	Silicon(SiO2)	50%	49%	1%
82	Chlorine(c1-)	50%	49%	1%
83	NO_2 (ពិនិត្យក្នុងពេល២៤ម៉ោង)	50%	49%	1%
84	SO_2 (ពិនិត្យក្នុងពេល២៤ម៉ោង)	50%	49%	1%

ល.រ	បរិយាយ	អត្រាបែងចែក		
		ថវិកាជាតិ	ក. បស្ត	ក. សហវ
85	TSP			
	ពិនិត្យក្នុងពេល1ម៉ោង	50%	49%	1%
	ពិនិត្យក្នុងពេល8ម៉ោង	50%	49%	1%
	ពិនិត្យក្នុងពេល២៤ម៉ោង	50%	49%	1%
86	PM10			
	ពិនិត្យក្នុងពេល1ម៉ោង	50%	49%	1%
	ពិនិត្យក្នុងពេល8ម៉ោង	50%	49%	1%
	ពិនិត្យក្នុងពេល24ម៉ោង	50%	49%	1%
87	PM2.5			
	ពិនិត្យក្នុងពេល1ម៉ោង	50%	49%	1%
	ពិនិត្យក្នុងពេល8ម៉ោង	50%	49%	1%
	ពិនិត្យក្នុងពេល24ម៉ោង	50%	49%	1%
88	Noise	50%	49%	1%
	ពិនិត្យក្នុងពេល8ម៉ោង	50%	49%	1%
	ពិនិត្យក្នុងពេល24ម៉ោង	50%	49%	1%
89	Vibration	50%	49%	1%
	ពិនិត្យក្នុងពេល8ម៉ោង	50%	49%	1%
	ពិនិត្យក្នុងពេល24ម៉ោង	50%	49%	1%

ល.រ	បរិយាយ	អត្រាបែងចែក		
		ថវិកាជាតិ	ក. បស្ល	ក. សហវ
ខ-ប្រភេទសេវាផ្សេងៗ				
1	ផ្តល់លិខិតអនុញ្ញាតបញ្ចេញសំណល់រាវចេញពីទីតាំងអាជីវកម្ម (តាមការស្នើសុំ)	50%	49%	1%
2	ផ្តល់លិខិតអនុញ្ញាតបញ្ចេញសំណល់រឹងចេញពីទីតាំងអាជីវកម្ម (តាមការស្នើសុំ)	50%	49%	1%
3	ផ្តល់លិខិតអនុញ្ញាតប្រមូលទិញសំណល់ដែលអាចកែច្នៃឡើងវិញ(តាមការស្នើសុំ)	50%	49%	1%
4	ផ្តល់លិខិតអនុញ្ញាតនាំចេញសំណល់ដែលអាចកែច្នៃ(ផលិតផលអេតចាយ)(តាមការស្នើសុំ)	50%	49%	1%
5	ផ្តល់លិខិតអនុញ្ញាតនាំចូលសារធាតុត្រជាក់	50%	49%	1%
6	ផ្តល់លិខិតអនុញ្ញាតនាំចូលសារធាតុធ្វើឱ្យត្រជាក់	50%	49%	1%
7	ថ្លៃឈ្នួលដីដាក់បង្គោលអង់តែនទូរស័ព្ទ ក្នុងតំបន់ការពារធម្មជាតិ (1ឆ្នាំ)	50%	49%	1%
8	វិភាគទានចូលក្នុងមូលនិធិទាយជ្ជទានបរិស្ថាន សម្រាប់ការស្តារបរិស្ថានឡើងវិញ	70%	29%	1%
9	ផ្តល់លិខិតអនុញ្ញាតនាំចេញ នាំចូលសារពាង្គកាយកែច្នៃរស់(ក្នុង 1មុខ)	50%	49%	1%
10	ការវិភាគសារពាង្គកាយកែច្នៃរស់(ក្នុង 1មុខ)	50%	49%	1%

បញ្ជាក់: ចំពោះចំណូលដែលប្រមូលបានពីការផ្តល់សេវាសាធារណៈដោយមន្ទីរបរិស្ថានរាជធានី ខេត្ត ការផ្តល់រង្វាន់លើកទឹកចិត្តជូនមន្ទីរបរិស្ថានរាជធានី ខេត្ត និងមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុរាជធានី ខេត្ត ត្រូវអនុវត្តដូចអត្រាដែលបានកំណត់ក្នុងតារាងឧបសម្ព័ន្ធនេះ។

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ធនាគារជាតិ នៃ កម្ពុជា

លេខ ធ៧-០១២-១៨៥ ប្រ.ក

ប្រកាស
ស្តីពី
វិធានប្រុងប្រយ័ត្ន និងការគ្រប់គ្រងហានិភ័យអនុវត្តចំពោះគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុដែលធ្វើជាភ្នាក់ងារទូទាត់សាច់ប្រាក់ពាក់ព័ន្ធនឹងមូលបត្រ

ទេសាភិបាលធនាគារជាតិនៃកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២៧ ចុះថ្ងៃទី២៦ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃធនាគារជាតិនៃកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០៦/០៣៦ ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០០៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មមាត្រា១៤ និងមាត្រា៥៧ នៃច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃធនាគារជាតិនៃកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/១១៩៩/១៣ ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១២/៣៣៧ ចុះថ្ងៃទី១៧ ខែមេសា ឆ្នាំ២០១២ ស្តីពីការតែងតាំង ឯកឧត្តម ជា ចាន់តូ ជាអគ្គទេសាភិបាល ធនាគារជាតិនៃកម្ពុជាជាថ្មី មានឋានៈស្មើទេសរដ្ឋមន្ត្រី
- យោងតាមប្រកាសលេខ ធ១-០១០-១៩៤ ប្រ.ក ចុះថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ២០១០ ស្តីពីការកែសម្រួលប្រការ៣ ប្រការ៤ ប្រការ៥ ប្រការ១២ និងប្រការ១៣ នៃប្រកាសស្តីពីរចនាសម្ព័ន្ធរបស់ធនាគារជាតិនៃកម្ពុជា និងមុខងារ-ភារកិច្ចរបស់បណ្តាអង្គភាពក្រោមឱវាទ
- យោងតាមស្មារតីអង្គប្រជុំរបស់ថ្នាក់ដឹកនាំធនាគារជាតិនៃកម្ពុជាចុះថ្ងៃទី១៧ ខែសីហា ឆ្នាំ២០១២

សម្រេច

ប្រការ ១.-

ប្រកាសនេះមានគោលបំណងកំណត់វិធានប្រុងប្រយ័ត្ន និងការគ្រប់គ្រងហានិភ័យអនុវត្តចំពោះគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុដែលធ្វើជាភ្នាក់ងារទូទាត់សាច់ប្រាក់ពាក់ព័ន្ធនឹងមូលបត្រ តទៅនេះហៅថា

ប្រអប់សំបុត្រលេខ ២៥, ឡូត៍លេខ ២២-២៤ មហាវិថី ព្រះនរោត្តម រាជធានីភ្នំពេញ, ទូរស័ព្ទ : (៨៥៥-២៣) ៧២២ ៥៦៣, ទូរស័ព្ទ . ទូរសារ : (៨៥៥-២៣) ៤២៦ ១១៧

"ធនាគារភ្នាក់ងារ" ដែលទទួលប្រតិស្រុតពីគណៈកម្មការមូលបត្រកម្ពុជា ឱ្យធ្វើសកម្មភាពជាត់ទាត់ ឬទូទាត់សាច់ប្រាក់សម្រាប់អតិថិជនរបស់ក្រុមហ៊ុនមូលបត្រ ដែលមានគណនីទូទាត់សាច់ប្រាក់ជាមួយធនាគារភ្នាក់ងារ។

ប្រការ ២.-

ធនាគារភ្នាក់ងារត្រូវរៀបចំប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង ដូចខាងក្រោមនេះ៖

១. ត្រូវកំណត់ឱ្យបានច្បាស់លាស់អំពី គោលនយោបាយ នីតិវិធី និងដំណើរការនៃការត្រួតពិនិត្យផ្ទៃក្នុងនិងការប្រតិបត្តិតាម ហើយតែងតាំងបុគ្គលិកមានចំណេះដឹងដែលបានទទួលការបណ្តុះបណ្តាលត្រឹមត្រូវឱ្យទទួលបន្ទុកការងារនេះ។ ការត្រួតពិនិត្យនេះត្រូវចាត់ទុកជាផ្នែកមួយនៃប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុងរបស់ធនាគារ ហើយត្រូវបានវាយតម្លៃឡើងវិញប្រចាំគ្រាអំពីប្រសិទ្ធភាព ភាពគ្រប់គ្រាន់ និងតម្រូវការក្នុងការកែលម្អ។

២. ត្រូវធានាឱ្យមាន ៖

ក. ការញែកឱ្យដាច់ពីគ្នារវាងដំណើរការទូទាត់សម្រាប់ប្រតិបត្តិការក្នុងទីផ្សារមូលបត្រ និងដំណើរការទូទាត់សម្រាប់សកម្មភាពប្រតិបត្តិការធម្មតា ដែលចែងក្នុងច្បាប់ស្តីពីគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ។

ខ. ការញែកឱ្យដាច់ពីគ្នារវាងគណនីអតិថិជនរបស់ក្រុមហ៊ុនមូលបត្រសម្រាប់ទូទាត់ប្រតិបត្តិការក្នុងទីផ្សារមូលបត្រកម្ពុជា និងគណនីប្រាក់បញ្ញើអតិថិជនធម្មតា។ គណនីទូទាត់របស់ក្រុមហ៊ុនមូលបត្រដែលមានឬគ្មានសិទ្ធិអំណាចជាអ្នកធានាទិញ ឬជួញដូរមូលបត្រ ក៏ត្រូវញែកឱ្យដាច់ពីគ្នា ដើម្បីចៀសវាងការលាយឡំគ្នារវាងសាច់ប្រាក់របស់អតិថិជនរបស់ក្រុមហ៊ុនមូលបត្រ និងប្រាក់បញ្ញើរបស់អតិថិជនធម្មតា។

គ. ដំណើរការទាំងអស់ដែលពាក់ព័ន្ធសម្រាប់ចាត់ចែង និងទូទាត់ប្រតិបត្តិការទិញ-លក់មូលបត្រត្រូវមានឯកសារយោងតាមលំនាំសវនកម្ម (Audit trail process) ដែលសមស្រប និងមានប្រសិទ្ធភាព។ ប្រសិទ្ធភាពនៃលំនាំសវនកម្មត្រូវបានធ្វើតេស្ត និងវាយតម្លៃឡើងវិញជាប្រចាំ។ ឯកសារនៃដំណើរការនិងនីតិវិធីទាំងនេះ ត្រូវបានធ្វើបច្ចុប្បន្នកម្ម និងរក្សាទុក។ ឯកសារយោងតាមលំនាំសវនកម្មត្រូវបានការពារ និងរក្សាទុកសម្រាប់រយៈពេលយ៉ាងតិច ៥ឆ្នាំ (ប្រាំឆ្នាំ) និងត្រូវផ្តល់ឱ្យស្នងការគណនីឯករាជ្យ គណៈកម្មការមូលបត្រកម្ពុជា និងធនាគារជាតិនៃកម្ពុជា តាមសំណើ។

ប្រការ ៣.-

១. ធនាគារភ្នាក់ងារមិនត្រូវផ្តល់ឥណទានវិបារូបន៍ ឬឥណទានផ្សេងទៀតដល់អតិថិជនរបស់ក្រុមហ៊ុនមូលបត្រក្នុងការប្រើប្រាស់សម្រាប់គោលបំណងទូទាត់ប្រតិបត្តិការទិញ-លក់ក្នុងទីផ្សារមូលបត្រកម្ពុជា។

២. ដើម្បីធានានូវការញែកឱ្យដាច់ពីគ្នារវាងគណនីទូទាត់សាច់ប្រាក់ពាក់ព័ន្ធនឹងមូលបត្ររបស់អតិថិជន ធនាគារភ្នាក់ងារមិនត្រូវប្រើប្រាស់សមតុល្យទឹកប្រាក់របស់អតិថិជននៃក្រុមហ៊ុនមូលបត្រជាប្រភពទុនសម្រាប់សកម្មភាពប្រតិបត្តិការធម្មតារបស់ធនាគារភ្នាក់ងារទេ។

៣. ក្នុងការគណនាអនុបាតសន្ទនីយភាព សមតុល្យគណនីទូទាត់សាច់ប្រាក់ពាក់ព័ន្ធនឹងមូលបត្ររបស់អតិថិជនរបស់ក្រុមហ៊ុនមូលបត្រ(ទ្រព្យអកម្ម) ត្រូវដកចេញពីភាគយក និងថ្លឹង១០០% (មួយរយភាគរយ) ក្នុងខ្ទង់ភាគបែង។

៤. គណនីទូទាត់សាច់ប្រាក់ពាក់ព័ន្ធនឹងមូលបត្ររបស់អតិថិជនរបស់ក្រុមហ៊ុនមូលបត្រនៅធនាគារភ្នាក់ងារមិនតម្រូវឱ្យតម្កល់ប្រាក់បម្រុងកាតព្វកិច្ចនៅធនាគារជាតិនៃកម្ពុជាទេ។

ប្រការ ៤.-

១. គណនីទូទាត់សាច់ប្រាក់ពាក់ព័ន្ធនឹងមូលបត្ររបស់ក្រុមហ៊ុនមូលបត្រនៅធនាគារភ្នាក់ងារមិនតម្រូវឱ្យតម្កល់ប្រាក់បម្រុងកាតព្វកិច្ចនៅធនាគារជាតិនៃកម្ពុជាទេ។

២. ក្នុងការគណនាអនុបាតសន្ទនីយភាព សមតុល្យគណនីទូទាត់សាច់ប្រាក់ពាក់ព័ន្ធនឹងមូលបត្ររបស់ក្រុមហ៊ុនមូលបត្រនៅធនាគារភ្នាក់ងារ ត្រូវដកចេញពីភាគយក និងថ្លឹង១០០% (មួយរយភាគរយ) ក្នុងខ្ទង់ភាគបែង។

ប្រការ ៥.-

១. ដោយពិនិត្យលើហានិភ័យនៃការបង្អាក់ដល់ដំណើរការទូទាត់និងផាត់ទាត់ជាទូទៅ ដែលបណ្តាលមកពីធនាគារភ្នាក់ងារខកខានក្នុងការទូទាត់ ឬផាត់ទាត់សាច់ប្រាក់ ធនាគារភ្នាក់ងារត្រូវបង្កើតផែនការយថាភាពនិងនិរន្តរភាពអាជីវកម្មសមស្រប ដោយមានដំណោះស្រាយបើកអាប់ (Back-up) គ្រប់គ្រាន់។

២. ការធ្វើផែនការយថាភាពនិងនិរន្តរភាពអាជីវកម្មនោះ ត្រូវពិចារណាទាំងលើការខកខាន ឬការបង្អាក់ដែលផ្តើមចេញពីធនាគារភ្នាក់ងារ និងពីកត្តាខាងក្រៅ។

៣. ត្រូវរៀបចំចងក្រងជាឯកសារ និងធ្វើតេស្តជាប្រចាំ ដើម្បីវាយតម្លៃឡើងវិញពីប្រសិទ្ធភាពនៃការធ្វើផែនការ នីតិវិធីនិងដំណើរការយថាភាពនិងនិរន្តរភាពអាជីវកម្ម។ ឯកសារទាំងនេះត្រូវបានរក្សាទុកជាកាលប្បវត្តិនិងធ្វើបច្ចុប្បន្នកម្ម។

៤. សវនកម្មផ្ទៃក្នុងរបស់ធនាគារភ្នាក់ងារ ត្រូវធ្វើការវាយតម្លៃដោយឯករាជ្យនិងជាប្រចាំលើផែនការ នីតិវិធីនិងដំណើរការបើកអាប់ (Back-up) ហើយគណៈគ្រប់គ្រងធនាគារភ្នាក់ងារត្រូវពិចារណា និងដោះស្រាយ ជាបន្ទាន់តាមអនុសាសន៍របស់សវនករផ្ទៃក្នុង។

ប្រការ ៦-

ធនាគារភ្នាក់ងារដែលមិនអនុវត្តតាមខ្លឹមសារនៃប្រកាសនេះ ត្រូវទទួលរងទណ្ឌកម្មខាងវិន័យដូចមានចែងក្នុងមាត្រា៥២ មាត្រា៥៣ និងមាត្រា៥៤ នៃច្បាប់ស្តីពីគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ។

ប្រការ ៧.-

អគ្គលេខាធិការដ្ឋាន អគ្គនាយកដ្ឋានត្រួតពិនិត្យ អគ្គនាយកដ្ឋានបច្ចេកទេស អគ្គាធិការដ្ឋាន អគ្គបេឡាគ្រប់នាយកដ្ឋាន និងអង្គភាពក្រោមឱវាទធនាគារជាតិនៃកម្ពុជា និងគ្រប់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ នៅក្រោមអាណាព្យាបាលធនាគារជាតិនៃកម្ពុជាត្រូវអនុវត្តម៉ឺងម៉ាត់នូវប្រកាសនេះតាមភារកិច្ចរៀងៗខ្លួន។

ប្រការ ៨.-

ប្រកាសនេះមានប្រសិទ្ធភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១២

ទេសាភិបាល

ជា.ចាន់តូ

កន្លែងទទួល

- ដូចប្រការ ៧ " ដើម្បីអនុវត្ត"
- ឯកសារ-កាលប្បវត្តិ

ចម្លងជូន

- គ្រប់សមាជិកក្រុមប្រឹក្សាភិបាល
- ទីស្តីការគណៈរដ្ឋមន្ត្រី
  " ដើម្បីជ្រាបជាព័ត៌មាន"
- នាយកដ្ឋានរដ្ឋបាលនៃទីស្តីការគណៈរដ្ឋមន្ត្រី
  " ដើម្បីចុះផ្សាយក្នុងរាជកិច្ច"

KINGDOM OF CAMBODIA
NATION RELIGION KING

NATIONAL BANK OF CAMBODIA

Number B7_012_185 Prorkor

Unofficial translation

PRAKAS
ON
PRUDENTIAL RULES AND RISK MANAGEMENT REQUIREMENTS APPLICABLE FOR BANKING AND FINANCIAL INSTITUTIONS ACTING AS CASH SETTLEMENT AGENTS RELATED TO SECURITIES

*****

The Governor of the National Bank of Cambodia

- With reference to the Constitution of the Kingdom of Cambodia;
- With reference to the Royal Kram NS/RKM/0196/27 of January 26, 1996 promulgating the Law on Organization and Conduct of the National Bank of Cambodia;
- With reference to the Royal Kram NS/RKM/1206/036 of December 29, 2006 promulgating the Law on the Amendment of article 14 and 57 of Organization and Function of the National Bank of Cambodia;
- With reference to the Royal Kram NS/RKM/1199/13 of November 18,1999 promulgating the Law on Banking and Financial Institutions;
- With reference to the Royal Decree NS/RKT/0412/337 of April 17, 2012 on the reappointment of **His Excellency Chea Chanto** as Governor General of the National Bank of Cambodia, equivalent to Senior Minister;
- With reference to Prkas No B1-010-194 Prokor dated 26 November 2010 on the amendment of Article 3, Article 4, Article 5, Article 12 and Article 13 of Prakas on Organization Structure of the National Bank of Cambodia and all departments of the National Bank of Cambodia;
- Pursuant to the recommendation made by National Bank of Cambodia Management meeting on 17 August 2012.

Decides:

Article 1.

The present Prakas aims at setting forth the prudential rules and risk management requirement applicable to the commercial banks acting as Cash Settlement Agent related to securities, hereafter called “Agent bank” which authorized by Securities Exchange Commission of Cambodia (SECC) for the purposes of settling the cash transactions generated by transactions performed by Securities Firms’ customers holding cash settlement accounts with Agent bank.

P.O Box 25, 22-24 Preah Norodom Blvd., Phnom Penh, Cambodia
Phone : 855 23 722563
Fax/Phone : 855 23 426117

Article 2.

Agent bank shall set up the internal control system as follow:

1. The Internal Controls and Compliance Control policies, procedures and processes shall be clearly defined and duly trained and knowledgeable individuals in charge of the performance of such controls shall be designated within the organization. Such Internal and Compliance Controls shall be considered as part of the overall Internal Control System of the Banks and shall be periodically reassessed in light of their effectiveness, adequacy and need for upgrading.

2. The Agent bank shall notably ensure for:

   a) Separate settlement processes for the purposes of settling transactions performed in the Stock Exchange Market and the ones carried out to support regular banking activities as foreseen by the Law on Banking and Financial Institutions;

   b) Segregation of accounts held with customers of securities firms in order to settle securities transactions performed with the Cambodian Stock Exchange and the ones held by regular depositors. Settlement accounts held by Securities Firms with or without underwriting or proprietary trading authorities shall be segregated as well in order to prevent from any possible commingling with securities customers' and regular depositors' moneys;

   c) All the processes involved for the purposes of organizing and settling Stock Exchange transactions shall be supported by appropriate and effective audit trail processes. Effectiveness of such audit trail processes shall be periodically tested and reassessed. The corresponding documentation of processes and procedures shall be subsequently updated and maintained; audit trail records shall be safeguarded and stored for a minimum of 5 years (five years) and provided, upon request, to External Auditors, SECC and NBC.

Article 3.

1. The Agent banks are prohibited from issuing overdraft or credit facilities to securities firms' customers for the purposes of settling their transactions with the Cambodian Stock Exchange.
2. To ensure for proper segregation of securities cash settlement accounts held by securities firms' customers with the Agent banks, such banks are prohibited from using such balances held as a regular funding source for the performance of their regular banking activities.
3. For the purposes of liquidity ratio calculation, such "Securities Firms' Customers-accounts (liabilities)" shall be deducted from numerator and weighted 100% in denominator.
4. Securities Firms' Customers-Accounts at Agent banks are not subject to reserve requirements to be maintained with the National Bank of Cambodia.

Article 4.

1. Cash Settlement Account-Balances maintained by Securities Firms with the Agent bank shall not be subject to reserve requirements to be maintained with the National Bank of Cambodia.

2. For the purposes of liquidity ratio calculation, Cash Settlement Account-Balances maintained by Securities Firms (liabilities) with the bank shall be deducted from numerator and weighted 100% in denominator.

Article 5.

1. Given the risk of disruption for the overall cash clearing and settlement processes represented by any failure originating with any of the Agent banks, the banks shall establish appropriate business contingency and continuity planning with adequate back-up solutions.
2. Such contingency and business continuity planning shall be considered in light of both, failures or disruptions originating within the Agent banks and external disruptions or failures.
3. Contingency and business continuity planning, procedures and processes shall be documented and periodically tested for reassessment of the effectiveness. Documentation shall be maintained up-to-date and results of testing performed shall be documented.
4. Internal audit of the bank shall perform periodic and independent assessments of planning; procedures and back-up processes, and audit recommendations shall be immediately considered by Agent bank management and addressed.

Article 6.

Agent banks which violate the provision of this Prakas may give rise to disciplinary sanction as set forth in Article 52, 53 and 54 of the Law on Banking and Financial Institutions.

Article 7.

The General Secretariat, the General Directorate of Supervision, the Technical General Directorate, the General Inspection, General Cashier, all departments of the National Bank of Cambodia, all Banking and Financial Institutions under the National Bank of Cambodia's supervisory authority shall strictly implement this Prakas.

Article 8.

This Prakas shall have effect from the signing date.

Phnom Penh, 31 December 2012

Governor

Signed and sealed: **Chea Chanto**

Cc: - All members of the Board of Directors
- The parties concerned as stated in article 7
- File
- CM " for info"
- Administration Department of CM
" for publication in the National Gazette"

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងបរិស្ថាន
Ministry of Environment

រាជធានីភ្នំពេញ, ថ្ងៃទី២៥ ខែមករា ឆ្នាំ២០១៣

លេខ: ០៥២ ល.-គ ប.ស្ល

ប្រកាស
ស្តីពីការដាក់ឲ្យអនុវត្តប្រកាសរួមស្តីពី ការផ្តល់សេវាសាធារណៈ និងការផ្តល់ទឹកប្រាក់លើកទឹកចិត្តជូនក្រសួងបរិស្ថាន

ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងបរិស្ថាន

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ នស.៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស.រកម ០១៩៦.២១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើ ច្បាប់ស្តីពីបង្កើតក្រសួងបរិស្ថាន
- បានឃើញព្រះរាជក្រឹត្យលេខ នស.រកត ០៩០៨.១០៥៧ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំង រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ៥៧អនក្រ.បក ចុះថ្ងៃទី២៥ ខែកញ្ញាឆ្នាំ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ របស់ក្រសួងបរិស្ថាន
- បានឃើញអនុក្រឹត្យលេខ ១០២ អនក្រ.បក ចុះថ្ងៃទី០៤ ខែតុលា ឆ្នាំ២០០១ ស្តីពីការតម្លើងនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុរបស់ក្រសួងបរិស្ថាន ទៅជាអគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៧២ អនក្រ.បក ចុះថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០០២ ស្តីពីតម្លើងអធិការដ្ឋានរបស់ក្រសួងបរិស្ថាន ទៅជាអគ្គាធិការដ្ឋាន
- យោងអនុក្រឹត្យលេខ ៣៧ អនក្រ.បក ចុះថ្ងៃទី២៤ ខែមេសា ឆ្នាំ២០០៨ ស្តីពីការតម្លើងនាយកដ្ឋានរដ្ឋបាលការពារ និងអភិរក្សធម្មជាតិរបស់ក្រសួងបរិស្ថាន ទៅជាអគ្គនាយកដ្ឋានរដ្ឋបាលការពារ និងអភិរក្សធម្មជាតិ
- ប្រកាសរួមលេខ: ៩៩៩ សហវ.ប្រក និងលេខ: ១០០០ សហវ.ប្រក ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ២០១២
- យោងការចាំបាច់របស់ក្រសួង

សម្រេច

ប្រការ១ : ត្រូវបានអនុញ្ញាតឲ្យអង្គភាពនៅរដ្ឋបាលកណ្តាលរួមមាន អគ្គនាយកដ្ឋានរដ្ឋបាលការពារ និងអភិរក្សធម្មជាតិ នាយកដ្ឋានត្រួតពិនិត្យការបំពុលបរិស្ថាន នាយកដ្ឋានអង្កេតពិនិត្យការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន នៃអគ្គនាយកបច្ចេកទេស លេខាធិការដ្ឋានជីវសុវត្ថិភាព និងគ្រប់មន្ទីរបរិស្ថានរាជធានី-ខេត្ត អនុវត្តការប្រមូលចំណូលពីកម្រៃសេវាសាធារណៈ ដើម្បីជាគុណប្រយោជន៍ថវិកាជាតិ។

- ត្រូវបានអនុញ្ញាតឲ្យអង្គភាពប្រមូលចំណូលដកទុកសម្រាប់ឧបត្ថម្ភជូនមន្ត្រី ដែលបំពេញភារកិច្ចផ្ទាល់ និងមន្ត្រីផ្សេងៗទៀត លើការបម្រើសេវាសាធារណៈ ព្រមទាំងសម្រាប់ពង្រឹងយន្តការប្រមូលចំណូល ។

ប្រការ២ : ការរៀបចំ និងការប្រព្រឹត្តទៅ នៃការប្រមូលចំណូល ការដកទុក ប្រាក់រង្វាន់លើកទឹកចិត្ត ក្រសួងនឹងមានសេចក្តីណែនាំអនុវត្តជាក់ស្តែងដោយឡែក។

ប្រការ៣ : គ្រប់អង្គភាពប្រមូលចំណូល ដូចប្រការ១ ត្រូវមានសេចក្តីកំណត់ជាក់ស្តែងអំពីការប្រមូលចំណូល ការដកទុកការបែងចែកប្រាក់រង្វាន់លើកទឹកចិត្តជូនមន្ត្រីដោយធានាឲ្យបានការឯកភាពផ្ទៃក្នុងអង្គភាពនីមួយៗ ។

ប្រការ៤ : ខុទ្ទកាល័យឯកឧត្តមទេសរដ្ឋមន្ត្រី អគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ អគ្គនាយកដ្ឋានរដ្ឋបាលការពារ និងអភិរក្សធម្មជាតិ អគ្គនាយកដ្ឋានបច្ចេកទេស អគ្គាធិការ គ្រប់មន្ទីរបរិស្ថានរាជធានី-ខេត្ត និងអង្គភាពពាក់ព័ន្ធ ត្រូវអនុវត្តប្រកាសនេះឲ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងបរិស្ថាន

មុំ_ម៉ារ៉ែត
បណ្ឌិត.ជីវិទ្យា

ចំលងជូន :

- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- គ្រប់អង្គភាពចំណុះក្រសួង
"ដើម្បីអនុវត្ត"
- ឯកសារ-កាលប្បវត្តិ